# ត្រៃភូជធម៌

និពន្ធនិងរៀបរៀង

ព្រះបាឡាត់ ស៊ុង-ស៊ីវ

**ធម៌ជាកំពូលលោកមាន៣យ៉ាង**

១- សច្ចំ ពោលពាក្យទៀងត្រង់

២- ខន្តី អត់ធន់ អំណត់គ្រប់យ៉ាង

៣- កតញ្ញូ ដឹងឧបការគុណរបស់អ្នកដទៃ ហើយធ្វើតបវិញ ។

បោះពុម្ពជាថ្មីឆ្នាំ ១៩៥៩

រក្សាសិទ្ធិ

LIBRARY BUDDHIST INSTITUTE

២៥៧.
៤១.២

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្ស៊ូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

២៥៧.
៤១ ខ

# អារម្ភកថា

សៀវភៅនេះខ្ញុំបានរៀបរៀងតាំងពី ព.ស. ២៤៩១ កាលដែលខ្ញុំនៅជាសិស្សសាលាបាលីជាន់ខ្ពស់នៅឡើយ ។ ការដែលរៀបរៀងនោះខ្ញុំបានដកស្រង់ពីគម្ពីរមហាបដ្ឋានត្រង់សរូបចតុព្វិបសតិច្ឆយវារៈ. គម្ពីរមជ្ឈិមនិកាយមជ្ឈិមបណ្ណាសកៈ. គម្ពីរវិសុទ្ធិមគ្គ និងមង្គលត្ថទីបនីជាដើមយកមកប្រែចងក្រងរៀបរៀង ។ លុះរៀបរៀងចប់ហើយបានយកទៅប្រគេនសម្តេចព្រះមហាសុមេធាធិបតី ( ជោតញ្ញាណោ ជ.ណ.) សង្ឃនាយក គណៈមហានិកាយ ពិនិត្យកែពិនិត្យហើយបានទេសនាផ្សាយតាមវិទ្យុកម្ពុជាក្នុងឆ្នាំនោះ. ដល់មក ព.ស. ២៤៩២ ពុទ្ធសាសនបណ្ឌិត្យបានយកធម៌នេះចុះផ្សាយតាមទស្សនាវដ្ដីក្នុងឆ្នាំនោះ ។ លុះដល់មកព.ស. ២៤៩៤ ថៅកែ ប៉ោ ហ៊ត បានអារាធនាអោយខ្ញុំដកស្រង់យកធម៌នេះមករៀបរៀងជាបែបសៀវភៅ ដើម្បីបោះពុម្ពផ្សាយទូទៅដល់សិក្ខាកាមនិករទាំងឡាយ. ខ្ញុំក៏បានដកស្រង់ជូនថៅកែ ប៉ោ ហ៊ត តាមពាក្យអារាធនា ។

**វត្តលង្កា ថ្ងៃទី ១១ កញ្ញា** ២៤៩៤ / ១៩៥១

ព្រះបាឡាត់ឧត្តមលិខិត **សុខ ស៊ីច**

**សិរីធម្មោ**

គ្រូបង្រៀនបាលីវត្តលង្កា

LIBRARY
BUDDHIST INSTITUTE
៥១៣៥/០០

## រតនប្រលោម

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

ខ្ញុំព្រះករុណា សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយគោរព ។

**សាធុ សាធុ ហន្ទ ចិហិតា ចិហិតា មយា**

**វន្ទនា វន្ទនា មាន ភាជនេ រតនត្តយេ ៥**

កិរិយាថ្វាយបង្គំឯណា ដែលខ្ញុំព្រះករុណា បានធ្វើឱ្យប្រកបដោយសេចក្តីគោរព ក្នុងប្រជុំបីនៃរតនៈ មានព្រះពុទ្ធជាដើម ដែលជាភាជនៈ គួរតែបុគ្គលថ្វាយបង្គំបូជា ដោយទ្វារទាំងបីមានកាយទ្វារជាដើម. កិរិយាថ្វាយបង្គំនោះឯង ជាអំពើដ៏វិសេស ព្រោះញ៉ាំងសម្បត្តិជាលោកិយ នឹងលោកុត្តរៈ ឱ្យសម្រេចបាន សូមញ៉ាំងសេចក្តីក្រវល់ក្រវាយ ដែលប្រព្រឹត្តទៅក្នុងកាយនិងចិត្តនៃខ្ញុំព្រះករុណាឱ្យវិនាសបាត់បង់ទៅ ។

*ព្រះបាឡាត់ឧត្តមលិខិត* ***សុខ ស៊ីវ***

**សិទ្ធត្ថោ**

# បញ្ជីមាតិកាធម៌

មាតិកានុក្រម លេខទំព័រ

ធម៌ជាកំពូលនៃលោក ៣ យ៉ាង ---------------------------- ១

នរកឈ្មោះកូដការី ---------------------------------- ៣

ធម៌ជាហេតុឱ្យកើតសច្ច -------------------------------- ៤

រឿងព្រះបាទសុនន្ទះនិងមនុស្សទោស ---------------------- ៩

រឿងកបិលយក្ខរាជ ---------------------------------- ១១

រឿងស្តេចត្រីរស់ ----------------------------------- ១៦

ខន្តិធម៌ ៣ យ៉ាង ----------------------------------- ១៩

បរមធម៌ក្នុងលោកិយនិងលោកុត្តរៈ ----------------------

រឿងបុរសជាប់ក្បាលក្នុងត្បាល់ ------------------------២៥

រឿងកង្កែបកើតជាទេវបុត្រ --------------------------- ២៧

កតញ្ញូតាធម៌ -------------------------------------- ២៩

រឿងត្មាតជាប់លប ----------------------------------៣១

រឿងនាងសិរិរតនាភា ------------------------------- ៣៣

រឿងកណ្តុរកើតជាខ្លា ------------------------------ ៣៨

រឿងមេគោកូនគោខ្លាធំ ------------------------------ ៣៩

ប្រៀបធៀបត្រៃកូដធម៌នឹងភ្នំសិលោរស្ថ -------------------៤១

# ត្រៃកូដធម៌

ធម៌ជាកំពូលនៃលោកបីយ៉ាងគឺ:

១. **សច្ចំ** សេចក្ដីពិតត្រង់.

២. **ខន្តិ** សេចក្ដីអត់ធន់

៣. **កតញ្ញុតា** សេចក្ដីដឹងគុណ

ធម៌ទាំងបីយ៉ាងនេះមានសំដែងជាបុគ្គលាធិដ្ឋានក្នុងគម្ពីរមហាបដ្ឋាន ត្រង់សរូបបតុព្វិសតិបច្ចយវារៈដូចតទៅនេះ ។

ធម៌ទាំងបីគឺ **សច្ចំ ខន្តិ កតញ្ញុតា** នេះឈ្មោះថាត្រៃកូដធម៌ ឬ ឧត្តមវរធម៌ឬថាបធានធម៌ ព្រោះធម៌ជាកំពូលនៃលោកប្រសើរវិសេសធំចម្បង ជាងធម៌ទាំងពួង ។

## សេចក្ដីអធិប្បាយ

ទី១-**សច្ចំ** សេចក្ដីពិតត្រង់ គឺមិននិយាយបំផ្លើសឱ្យលើសពីសភាវៈពិត បើឃើញថាឃើញ. ខុសថាខុស. ត្រូវថាត្រូវដូច្នេះជាដើម ហៅថាសច្ចៈ សេចក្ដីពិត ។

ពាក្យថាសច្ចៈនេះ មានន័យចែកចេញជាច្រើនយ៉ាង ក្នុងទីនេះនឹងលើក យកតែត្រង់ន័យដែលចែកជា ៦ យ៉ាងមកអធិប្បាយដូចតទៅនេះ ។

សច្ចៈចែកជា ៦ យ៉ាងគឺ:

១.**វាចាសច្ចៈ** ពិតខាងផ្លូវវាចា

**២-សម្មតិសច្ចៈ** ពិតខាងការសន្មតិ

**៣-សភាវសច្ចៈ** ពិតខាងសភាវៈ

**៤-បរមត្ថសច្ចៈ** ពិតខាងផ្លូវបរមត្ថ

**៥-អរិយសច្ចៈ** ពិតរបស់អរិយបុគ្គល

**៦-និព្វានសច្ចៈ** ពិតខាងព្រះនិព្វាន

## ១) វាចាសច្ចៈ

ពិតខាងផ្លូវវាចា គឺមិននិយាយអោយលើសហួសហេតុដែលកើតមានឡើង បើហេតុនោះមានថាមាន. មិនមានថាមិនមាន. ល្អថាល្អ. អាក្រក់ថាអាក្រក់. ខុសថាខុស. ត្រូវថាត្រូវដូច្នេះជាដើម ហៅថាវាចាសច្ចៈ ។

បណ្ឌិតទាំងឡាយដែលសំដែងនូវសច្ចៈក្នុងបករណ៍ទាំងពួង ច្រើនសំដៅយកវាចាសច្ចៈនេះជាងសច្ចៈដទៃៗ ព្រោះការពិតក្តីមិនពិតក្តី ដែលគេអាចដឹងបានច្រើនដឹងដោយវាចា ។

ពាក្យសំដីពិតនេះព្រះសម្ពុទ្ធទ្រង់ត្រាស់សរសើរថា ជាវាចាមិនចេះស្លាប់ ទោះបីបុគ្គលអ្នកពោលនោះស្លាប់បាត់បង់ទៅហើយក៏ដោយ ឯវាចាពិតរបស់បុគ្គលនោះ នៅតែរស់រវើកព្រោះជាវាចាធ្វើឱ្យសម្រេចប្រយោជន៍គ្រប់យ៉ាង ពួកបណ្ឌិតទាំងឡាយតែងលើកដំកើងឱ្យពរសព្ទសាធុការអស់កាលជានិច្ច ដូចយ៉ាងពុទ្ធឱវាទរបស់ព្រះអរហន្តព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ព្រះអង្គបរិនិព្វានទៅជាង ២០ សតវត្សហើយ ឯពុទ្ធឱវាទគឺពាក្យប្រៀនប្រដៅរបស់ព្រះអង្គទាំង

ប៉ុន្មានគង់វង្សនៅដដែលឥតមានបាត់បង់ទៅណាឡើយ បើចាប់លើកគម្ពីរសាស្ត្រមើលឡើង ឬស្តាប់អំពីសំណាក់លោកអ្នកជាពហុស្សូតវេលាណា ក៏ហាក់ដូចជាព្រះអង្គទ្រង់សំដែងប្រោសប្រទានក្នុងវេលានោះ ។

ន័យនេះសមនឹងពុទ្ធភាសិតថា:

**សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ**

**សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា ១**

សេចក្តីថា: ពាក្យពិត ជាវាចាមិនស្លាប់ ពាក្យពិតនេះជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ តែងសន្សំហើយក្នុងកាលមុន អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងស្ថិតនៅក្នុងសច្ចធម៌ ព្រោះធម៌ជាប្រយោជន៍ដល់ខ្លួនផងដល់បុគ្គលដទៃផង តាមធម្មតាមិនប្រែប្រួលឡើយ ។

សត្វទាំងឡាយក្នុងលោកបើគ្មានសច្ចៈការពិតត្រង់នេះទេ តែងតែជួបប្រទះនឹងគំនរសេចក្តីទុក្ខលំបាកជានិច្ច ដូចមាននិទានមួយក្នុងនេមិរាជជាតកថា មាននរកមួយឈ្មោះ កូដការី សត្វក្នុងនរកនោះមានពួក នាយនិរយបាល យកសន្ទូចដែកមានផ្លែនិងដងធំៗ ប៉ុនដើមត្នោត ផ្គក់កៅទាញអណ្តាតយកទៅសនឹងលើផ្ទាំងដែកដែលភ្លើងឆេះក្រហម ដូចជាគេបោះសន្ទឹងស្បែកស្រស់ភ្ជាប់លើផែនដី ។ សត្វនរកនោះឈឺផ្សារអន្ទះអន្ទែងបំរះរាលនទៀលយំស្រែកហូរទឹកមាត់ទឹកភ្នែកសស្រាក់ ឧបមាដូចជាត្រីដែលគេចាប់ពីក្នុងទឹកបោះទៅលើគោក ។ នៅរងទុក្ខតែយ៉ាងនេះរាប់ពាន់រាប់ហ្មឺនឆ្នាំ ពុំមានពេលណាមួយដែលសត្វនរកនេះ បានស្រាកស្រាន្តចាកសេចក្តីទុក្ខនោះឡើយ ។

កម្មដែលនាំឱ្យធ្លាក់នរកនេះ មកអំពីជាតិមុន ជាមនុស្សគ្មានពាក្យសច្ចៈ និយាយដំឡើងថ្លៃទំនិញច្រើនហួសហេតុ មិនសមនឹងវត្ថុរបស់ខ្លួន ព្រោះឃើញការចំណេញខ្លាំងពេក. ដូចមាននិពន្ធជាគាថាថា:

យេកេចិ សណ្ឋានគតមនុស្សា
អគ្ឃេន អគ្ឃំ កយំ ហាបយន្តិ
កូដេន កូដំ ធនលាភហេតុ
ឆន្នំ យថា វារិចរំ វធាយ
នហិ កូដការិស្ស ភវន្តិ តាណា
សកេហិ កម្មេហិ បុរក្ខិតស្ស
តេ លុទ្ទកម្មា បសវេត្វ បាបំ
តេមេ ជនា វេទ្ធយស្ម៉ា សយន្តិ ។

សេចក្តីថា: បុគ្គលបានវាយថ្លៃលក់របស់ ហើយវាយថ្លៃកោងអាក្រក់វៀចវេរ ព្រោះហេតុចង់បានទ្រព្យ ឯពាក្យសំដីទន់ភ្លន់ផ្អែមពិរោះដើម្បីបិទបាំងលាក់អំពើកោងវៀចវេររបស់ខ្លួន ដូចជាមនុស្សដែលអែបខ្លួនពួនចាំបាញ់សត្វ អ្នកដែលអាក្រក់វៀចវេរដូច្នេះ រមែងមិនមានអ្វីពឹងផ្អែកកុំឱ្យធ្លាក់នរកបានឡើយ កាលបើស្លាប់ហើយក៏តែងតែត្រូវសន្ទូចថ្កក់អណ្តាតក្នុងនរកនេះ ។

## ២) សម្មតិសច្ចៈ

ពិតខាងការសន្មតិ ពាក្យថាសន្មតិ គឺ: ការប្ដេជ្ញា. ការសន្យា. អនុម័តិ.

ការយល់ព្រមជាមួយ.ការតាំង. ដំណើរព្រមតាម. ការកំណត់ក្នុងទីនេះអដ្ឋកថា សំដៅយកការកំណត់ គឺកំណត់ថា: យើង. គេ. មនុស្ស. សត្វ. បុរស. ស្ត្រីជាដើម ។ ការកំណត់យ៉ាងនេះចាត់ជាការពិតមួយ ដូចពាក្យថា: មនុស្សនឹងសត្វដែលធ្លាប់កំណត់ចំណាំមកយូរហើយ ការកំណត់នោះនៅទៀងទាត់ឥតផ្លាស់ប្តូរ នឹងថាមនុស្សជាសត្វ១ ជាមនុស្សដូច្នេះវិញពុំដែលមាន ព្រោះមនុស្សមានលក្ខណៈសណ្ឋានទ្រង់ទ្រាយផ្សេងពីសត្វ។ យ៉ាងនេះជាដើមហៅថាសម្មតិសច្ចៈ។

## ៣) ភាវសច្ចៈ

ពិតខាងសភាវៈ បានដល់សត្វនឹងសង្ខារដែលតែងតែវិនាស ប្រែប្រួលទៅតាមធម្មតារបស់ខ្លួន នឹងបំបែរថា សត្វនឹងសង្ខារទៀងទាត់ស្ថិតស្ថេរ មិនវិនាស មិនប្រែប្រួលដូច្នេះវិញពុំបាន ព្រោះសត្វនឹងសង្ខារនេះជាពួកក្រុមរបស់អវិជ្ជា ទៀងតែវិនាសប្រែប្រួលដោយពិតប្រាកដ ។ យ៉ាងនេះជាដើមហៅថា ភាវសច្ចៈ ពិតខាងសភាវៈ ។

## ៤) បរមត្ថសច្ចៈ

ពិតខាងផ្លូវបរមត្ថ បានដល់ចិត្ត. ចេតសិក. រូប. និព្វាន ។ បរមត្ថធម៌ទាំងនេះមានពិតប្រាកដ ទៀងទាត់មិនចេះច្រឡូកច្រឡំផ្លាស់ប្តូរគ្នា ចិត្តជាចេតសិក១ ជារូប១ ជានិព្វានឡើយ គឺនៅទៀងពិតប្រាកដដដែលដូចសភាវៈដើម បើចិត្តនៅជាចិត្ត. ចេតសិកនៅជាចេតសិក. រូបនៅជារូប. និព្វាននៅជានិព្វាន. សូម្បីព្រះពុទ្ធអង្គណាសំដែងឡើងក៏នៅតែ ចិត្ត. ចេតសិក. រូប. និព្វាន

ដូចដែលឥតមានល្បៀង ។ យ៉ាងនេះជាដើមហៅថា បរមត្ថសច្ចៈ ពិងខាងផ្លូវបរមត្ថ ។

## ៥) អរិយសច្ចៈ

ពិតរបស់អរិយបុគ្គល បានដល់អរិយសច្ចធម៌ដែលព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាដើម យល់ឃើញច្បាស់លាស់ដោយញាណដ៏ប្រសើរ ។ អរិយសច្ចធម៌នោះមាន ៤ យ៉ាងគឺ :

(១). **ទុក្ខៈ** សេចក្តីព្រួយលំបាក

(២) **សមុទយៈ** កំណើតទុក្ខ ឬហេតុដែលនាំឱ្យកើតទុក្ខ

(៣) **និរោធៈ** សេចក្តីរលត់ទុក្ខ ឬធម៌សំរាប់រលត់ទុក្ខ

(៤) **មគ្គៈ** ផ្លូវឬឧបាយនៃសេចក្តីរលត់ទុក្ខ ។

ធម៌ទាំង ៤ នេះហៅ អរិយសច្ច ពិតវិសេសឥតមានល្បៀងនឹងបំបែរថាជាមិនពិតវិញពុំបានឡើយ [១] ។

## ៦) និព្វានសច្ចៈ

ពិតខាងព្រះនិព្វាន ពាក្យថានិព្វាន ប្រែថា ព្រះធម៌រលត់កិលេស. រលត់បញ្ចក្ខន្ធ គឺ លោកុត្តរធម៌ទី ៩ ដែលកើតអំពីលោកុត្តរធម៌ទាំង ៨ ខាងដើម (មគ្គ ៤ ផល ៤) ។ បានជាហៅថានិព្វានសច្ចៈ ព្រោះព្រះនិព្វានទៀងទាត់ប្រាកដគ្រប់យ៉ាង គឺមិនចេះត្រឡប់វិលវល់កើត ចាស់ ឈឺស្លាប់ មិនស្លាប់បង្ខាប់

---

១-អរិយសច្ចទាំង ៤ នេះ មានពិស្តារក្នុងសៀវភៅ អរិយមគ្គាធិប្បាយ ។

តណ្ហា មិនលុះទៅក្នុងអំណាចរបស់អវិជ្ជា មានតែសេចក្ដីសុខម្យ៉ាងដែលហៅថា ឯកន្តបរមសុខ សុខដ៏ក្រៃលែងឥតមានគូប្រដូច សុខដ៏ក្រៃលែងដោយចំណែកមួយ ទៀងទាត់ពិតប្រាកដ មិនវិលត្រឡប់ប្រែក្លាយជាទុក្ខវិញឡើយ ព្រោះកំចាត់បង់នូវឫសគល់នៃសេចក្ដីទុក្ខអស់ឥតមានសេសសល់បន្តិចបន្តួច ។ យ៉ាងនេះជាដើមហៅថានិព្វានសច្ចៈ ។

ក៏សច្ចៈធម៌នេះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងដោយពិស្ដារក្នុងសុត្តន្តបិដកគម្ពីរមជ្ឈិមនិកាយមជ្ឈិមបណ្ណាសកៈ ទ្រង់ចង្កីសូត្រ ក្នុងសូត្រនោះមានសេចក្ដីដំណាលថាៈ មានមាណពម្នាក់ឈ្មោះកាបទិកៈ[illegible]កោររលឹងមានអាយុ ១៦ ឆ្នាំ ពីកំណើតចេះចប់ត្រៃវេទព្រមទាំងគម្ពីរនិឃណ្ឌុនឹងគម្ពីរកេដុភៈព្រមទាំងអក្ខរប្បភេទ គឺសិក្ខានឹងនិរុត្តិ ដែលមានគម្ពីរឥតិហាសជាគំរប់ ៥ ជាអ្នកស្គាល់នូវបទនឹងវេយ្យាករណ៍ ជាអ្នកមិនខិនថយគឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រនឹងមហាបុរិសលក្ខណព្យាករណសាស្ត្រ បានសួររកធម៌ដែលនាំឱ្យកើតសច្ចៈ ចំពោះព្រះមានព្រះភាគ។ ទ្រង់ឆ្លើយតបថាៈ ម្នាលកាបទិកៈសច្ចៈគឺសេចក្ដីពិតត្រង់កើតឡើងដោយអាស្រ័យការព្យាយាម។ កើតឡើងដោយអាស្រ័យការពិចារណា ។ កើតឡើងដោយអាស្រ័យការប្រឹងប្រែង។ កើតឡើងដោយអាស្រ័យឆន្ទៈការពេញចិត្ត។ កើតឡើងដោយអាស្រ័យការចូលចិត្តធម៌ក្នុងគំនិត។ កើតឡើងដោយអាស្រ័យការពិចារណានូវអត្ថ ។ កើតឡើងដោយអាស្រ័យការចេះចាំនូវធម៌ ។ កើតឡើងដោយអាស្រ័យការស្ដាប់ធម៌ ។ កើតឡើងដោយអាស្រ័យការផ្ទង់ត្រចៀកប្រុងស្ដាប់។ កើតឡើងដោយអាស្រ័យ

ការចូលទៅអង្គុយជិត១ កើតឡើងដោយអាស្រ័យការចូលទៅរក១ កើតឡើងដោយអាស្រ័យសទ្ធាសេចក្តីជឿ. បើបុគ្គលណាគ្មានសទ្ធាហើយការចូលទៅរកក៏មិនមាន. ការចូលទៅអង្គុយជិតក៏មិនមាន. ការពិចារណានូវអត្ថ ក៏មិនមាន. សេចក្តីចូលចិត្តធម៌ក្នុងគំនិតក៏មិនមាន. ឆន្ទៈការពេញចិត្តក៏មិនមាន. ការប្រឹងប្រែងក៏មិនមាន. ការពិចារណាក៏មិនមាន. សេចក្តីព្យាយាមក៏មិនមាន. សច្ចៈសេចក្តីពិតត្រង់ក៏មិនមាន. បុគ្គលនោះលែងស្គាល់ខុសត្រូវ. គុណទោស. បុណ្យបាបលុះទៅក្នុងអំណាចនៃលោភៈ ទោសៈ មោហៈ ការដែលមិនពិតបានថាពិត សេចក្តីខុសបានថាត្រូវ គិតឃើញតែប្រយោជន៍ផ្ទាល់ខ្លួន មិនឃើញសេចក្តីទុក្ខរបស់អ្នកដទៃ. មនុស្សបែបនេះនឹងក្លាយខ្លួនទៅជាអប្បេសក្ខបុគ្គលរកសុគតិនិព្វានឈានសមាបត្តិមិនឃើញឡើយ ពីព្រោះសព្វសត្វទាំងអស់ក្នុងពិភពលោកដែលបែរមុខឆ្ពោះសញ្ចរទៅរកវឌ្ឍនធម៌បាន ដោយសារតែមានសច្ចៈជាចន្ទល់ជួយទល់ទ្រ បើប្រាសចាកសច្ចៈហើយនឹងរកវឌ្ឍនធម៌ពុំឃើញឡើយ ។ ដូចជាក្នុងលោកសព្វថ្ងៃនេះ បើប្រទេសណាមិនមានសច្ចៈធម៌ដល់គ្នានឹងគ្នាគឺ ពួកពលរដ្ឋគ្មានសច្ចៈពិតត្រង់ចំពោះព្រះមហាក្សត្រនឹងពួកសេវកាមាត្យ១ ក៏គ្មានសច្ចៈពិតត្រង់ចំពោះព្រះមហាក្សត្រនិងពលរដ្ឋ ប្រទេសនោះមិនអាចធាត់ធំស្គាល់បរិបូណ៌ ដោយមហិទ្ធិឫទ្ធិឡើយ មុខជានឹងស្គមស្គិតឥតឫទ្ធិអំណាចពួកវិទេសជនទាំងឡាយ នឹងជិះជាន់កកេរជញ្ជក់យកសាច់ឈាម នឹងក្លាយទៅប្រទេសទាបទាសទុព្វលភាពមិនខាន ។

មួយទៀត សូម្បីមាតាបិតានឹងបុត្រាបុត្រីស្វាមីនិងភរិយា ឬក៏គ្រូ

ឧបជ្ឈាយាចារ្យនិងសិស្សានុសិស្ស បើគ្មានសច្ចៈពិតត្រង់ទៅវិញទៅមកទេ សេចក្ដីវិនាសតែងកើតប្រាកដដល់ជនទាំងឡាយនោះ ។

សច្ចៈធម៌នេះជាធម៌ប្រសើរបំផុតក្នុងលោកបានជាព្រះសម្ពុទ្ធជាអគ្គបុគ្គល ទ្រង់សំដែងថា :

**សច្ចំ បរមំ លោកេ សច្ចំ លោកេ បធានកំ**

**សច្ចម្ហិ ឋិតមានស្មិំ សព្វបុញ្ញា ឋិតា ២**

សេចក្ដីថា: សច្ចៈជាធម៌ដ៏ឧត្ដមក្នុងលោក សច្ចៈធម៌ជាប្រធានក្នុងលោក ក៏បុណ្យទាំងអស់រមែងមានក្នុងសច្ចៈធម៌ ។

បើប្រាសចាកសច្ចៈហើយបុណ្យក៏មិនមាន បើគ្មានបុណ្យហើយរមែងបាន ជួបតែនឹងសេចក្ដីទុក្ខលំបាកល្ងង់ខ្លៅ ក្រីក្រថោកទាបជានិច្ច ព្រោះហេតុនោះ លោកអ្នកសប្បុរសទាំងឡាយគួរខំញ៉ាំងសច្ចៈគឺសេចក្ដីពិតត្រង់ឱ្យកើតមានឡើង គ្រប់ ១ គ្នា ។

បើមានសច្ចៈធម៌នេះស្ថិតនៅជាប់ប្រាកដក្នុងសន្ដានហើយ ទោះបីមាន ទោសកំហុសយ៉ាងណាក៏អាចដោះខ្លួនឱ្យរួចអំពីទោសកំហុសនោះបាន ដូចមាន រឿងមួយក្នុងគម្ពីរសំស្ក្រឹតថា:

ក្នុងកាលមុនមានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមសុនន្ទៈ សោយរាជ សម្បត្តិក្នុងនគរឈ្មោះបារសីកៈ ។ កាលថ្ងៃមួយព្រះរាជាអង្គនេះស្ដេចយាងទៅ ទតមនុស្សទោសក្នុងគុក ជាមួយពួកសេវកាមាត្យរបស់ព្រះអង្គ. ទ្រង់បានទត ឃើញបុរស ៤ នាក់ដែលមានទោសកំហុសនៅក្នុងគុក ក៏មានព្រះរាជហឫទ័យ

អាណិតចំពោះបុរសទាំងនោះ ទើបមានព្រះរាជឱង្ការត្រាស់សួរទៅបុរសទាំងនោះថា អ្នកទាំងឡាយដែលមកជាប់ទោសយ៉ាងនេះ តើមានកំហុសដូចម្ដេច? បណ្ដាមនុស្សទោសទាំង ៤ នោះ មនុស្សទោសទី១ ក្រាបបង្គំទូលថា: សូមទ្រង់ព្រះមេត្តាប្រោសកំហុសរបស់ទូលព្រះបង្គំពុំមានទេ គឺសាក្សីទី ១ ជាអ្នកពោលពាក្យមិនពិត ឆ្លើយទម្លាក់ទោសមកលើទូលព្រះបង្គំ ។

មនុស្សទោសទី ២ ក្រាបទូលថា: កំហុសរបស់ទូលព្រះបង្គំនេះ គឺ ចៅក្រមម្នាក់ស្អប់ទូលព្រះបង្គំតាំងពីដើមមក ព្រោះហេតុនោះបានជាចៅក្រមនោះចាប់ទូលព្រះបង្គំមកដាក់គុក ។

មនុស្សទោសទី ៣ ក្រាបបង្គំទូលថា: កំហុសរបស់ទូលព្រះបង្គំពុំមានទេ គឺចៅក្រមជាមនុស្សល្ងង់មិនដឹងនូវសេចក្ដីពិតតាមច្បាប់ មិនបានពិចារណាឱ្យត្រឹមត្រូវស្រាប់តែទម្លាក់ទោសកំហុសមកលើរូបទូលព្រះបង្គំ ដែលជាមនុស្សឥតទោសឱ្យជាអ្នកមានទោស ។

លំដាប់នោះមនុស្សទោសទី ៤ ជាអ្នកមានសច្ចៈធម៌ធ្លាប់ពោលតែពាក្យពិត ក៏ក្រាបបង្គំទូលព្រះរាជាថា: បពិត្រមហារាជទូលព្រះបង្គំបានលួចយកហឹបមួយដែលពេញដោយទ្រព្យ ក្នុងផ្ទះអ្នកមានទ្រព្យម្នាក់ក្នុងវ៉្យាឃ្របូរី ព្រោះហេតុនោះបានជាចៅក្រមទាំងឡាយដាក់ទណ្ឌកម្មចំពោះរូបទូលបង្គំដូច្នេះ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ក៏ទ្រង់ត្រាស់បង្គាប់ឱ្យចាងហ្វាងគុកដោះមនុស្សទាំង ៤ ដែលបាននិយាយពាក្យសច្ចៈនោះលែងឱ្យរួចពីគុកទៅ ។ ចាប់តាំងពីថ្ងៃនោះមកមនុស្សទោសនោះ ក៏លះបង់នូវចោរកម្មលែងប្រព្រឹត្តត

ទៅទៀត ។ ដែលបានរួចខ្លួនពីគុកយ៉ាងនេះក៏ព្រោះតែមានសច្ចៈធម៌ ។

ម្យ៉ាងទៀត បណ្ឌិតទាំងឡាយតែងកំចាត់បង់នូវពិសដ៏ក្លាហានបានក៏ដោយសារតែពាក្យសច្ចៈ ដូចមានបទសុភាសិតថាៈ វិសំបិ សច្ចេន ហនន្តិ បណ្ឌិតា" បណ្ឌិតទាំងឡាយកំចាត់បង់ពិសបានដោយពាក្យសច្ចៈ ។ សូមនាំនិទានជាតកមួយមកប្រៀបផ្ទឹមនឹងបទសុភាសិតនេះ ដើម្បីជាភស្តុតាងឱ្យចែងជាក់ច្បាស់. និទាននោះថាៈ

កាលព្រះសព្វញ្ញុពុទ្ធបរមគ្រូរបស់យើងទាំងឡាយនៅកំពុងសាងបារមីធម៌នៅឡើយ. កាលនោះព្រះអង្គទ្រង់ទទួលបដិសន្ធិភាពក្នុងផ្ទៃនៃនាងទុបារិកាជាភរិយារបស់ទុកុលតាបស ។ ឯទុកុលតាបសនិងនាងទុបារិកានេះជាបុត្រធីតារបស់នាយនេសាទពីរនាក់ ម្នាក់នៅត្រើយស្ទឹងខាងអាយ ម្នាក់ទៀតនៅត្រើយស្ទឹងខាងនាយ អ្នកនេសាទទាំងពីរនេះជាសំឡាញ់នឹងគ្នា ទើបរៀបផ្សំផ្គុំទុកុលនឹងនាងបារិកាដែលជាបុត្តធីតាឱ្យជាគូស្វាមីភរិយា ។ ឯទុកុលៈនិងនាងទុបារិកាគ្មានសេចក្តីស្ម័គ្រស្នាគមជាមួយគ្នាឡើយ ដោយហេតុទើបនឹងចុះពីស្ថានព្រហ្មមកកើត ។ លុះមាតាបិតារៀបអាពាហ៍ពិពាហ៍ឱ្យហើយ វេលាណាក៏មិនបានរួមរស់មេត្រីនឹងគ្នាឡើយ បែរជាបបួលគ្នាលាមាតាបិតាចេញទៅបួសជាតាបសឥសីទាំងពីររូបវិញ ហើយទៅនៅក្នុងសាលា ដែលព្រះឥន្ទប្រើវេស្សកម្មទេពឱ្យនិម្មិតថ្វាយក្នុងព្រៃហេមពាន្តឯណោះ ។ ខាងក្រោយមកសក្កទេវរាជទ្រង់ជ្រាបបុព្វកម្មតាបសទាំងពីរនោះថា ដល់ចាស់ជរានឹងខ្វាក់ភ្នែកអស់ទាំងពីរនាក់ គ្មាននរណានឹងថែរក្សាឡើយ ទើបទៅប្រាប់តាបសទាំងពីររូបឱ្យរួមរស់មេត្រី ដើម្បី

ឱ្យមានបុត្រ ។ តាបសនោះមិនព្រមទើបសុំអង្វរឱ្យគ្រាន់តែស្ទាបព្រះឧទរនាងទុបារិកា ក៏ព្រមធ្វើតាមដោយទើសទាល់ ។ លំដាប់នោះ សក្កទេវរាជទៅអញ្ជើញព្រះបរមពោធិសត្វឱ្យច្យុតចុះពីទេវលោកមកទទួលបដិសន្ធិក្នុងផ្ទៃនាងទុបារិកាបសិនី ។ លុះព្រះនាងមានគភ៌គ្រប់ដប់ខែហើយក៏ប្រសូត្របុត្រមក បានឱ្យឈ្មោះបុត្រនោះថាសុវណ្ណសាម ។ កុមារនេះដឹងក្តីឡើងកាលណាក៏ខំបំរើមាតាបិតាដ៏ប្រណីតតាបសទាំងពីរស្រឡាញ់សុវណ្ណសាមជាបុត្រស្មើដោយជីវិតតែងនាំគ្នាទៅបេះផ្លែឈើជីកគាស់មើមឈើ មានមើមដំឡូងជាដើមយកមកចិញ្ចឹមជីវិតទាំងបីរូបតែរាល់ថ្ងៃ ។ ឯសុវណ្ណសាមកាលបើមាតាបិតាទៅព្រៃបាត់ហើយ ក៏រៀបចំបោសសំអាតទីកន្លែងដងទឹកដុតភ្លើងចាំមាតាបិតា ។ ថ្ងៃមួយតាបសទាំងពីរទៅបេះផ្លែឈើក្បែរដំបូកមួយស្រាប់តែពស់កំណាចព្រួសពិសត្រូវភ្នែកខ្វាក់ទាំងពីរនាក់ រកផ្លូវដើមមកអាស្រមវិញពុំឃើញ ក៏នាំគ្នាស្រែកយំរៀបរាប់អាណិតដល់កូនដែលនៅចាំអាស្រមមិនដឹងជាទទឹងមើលផ្លូវយ៉ាងណាព្រោះពេលក៏ល្ងាចណាស់ទៅហើយ ។ ផ្ទែងពីសុវណ្ណសាមកាលបើថ្ងៃរសៀលទោរទាបជិតមាត់ព្រៃហើយ ពុំឃើញមាតាបិតាដូច្នោះ ក៏ភិតភ័យញ័ររន្ធត់ស្លុតអស់ទាំងអង្គកាយខំដើរចូលទៅក្នុងព្រៃស្រែកហៅមាតាបិតាលុះចូលជ្រៅទៅៗ បញ្ចារុក្ខាទាំងឡាយ ក៏បិទបាំងពន្លឺព្រះអាទិត្យជិតឈឹងពេលនោះតាបសទាំងពីរកំពុងតែដឹកដៃគ្នាយំរៀបរាប់ ក៏ស្រាប់តែឮសំឡេងសុវណ្ណ-សាម ទើបស្រែកហៅថាម្នាលបាដួងជីវិតអ្នកចូលមកយើងនៅក្នុងទីនេះ ។ សុវណ្ណសាម ក៏ស្ទុះចូលទៅឃើញមាតាបិតាខ្វាក់ភ្នែកអស់ដូច្នោះ មានចិត្តតក់

ស្ទុតរន្ធត់ខ្លាំងសន្លប់ដួលដេកលើប្រឹថពី លុះមានស្មារតីឡើងវិញក៏នាំមាតាបិតាមកអាស្រម ។ តពោ បង្ហាយ តាំងពីថ្ងៃនោះមកសុវណ្ណសាមធ្វើការបំរើមាតាបិតាទាំងពីរដោយឥតធុញទ្រាន់ឡើយ ទាំងខ្លួនសោតក៏ខំបំពេញព្រហ្មចរិយធម៌ជាប់ជានិច្ច ។ ដោយអំណាចនៃកុសលធម៌ សុវណ្ណសាមទៅក្នុងទីណាតែងមានហ្វូងម្រឹគចោមជាបរិវារឥតមានសត្វណាមួយបៀតបៀនឡើយ ។ ថ្ងៃមួយសុវណ្ណសាមបោសសំអាតអាស្រមធ្វើវត្តមាតាបិតាដោយគោរព ហើយកាន់ក្អមទៅដងទឹកក្នុងស្ទឹងមិគសមតាហ្វូងម្រឹគទាំងឡាយក៏ចោមរោមតាមទៅជាបរិវារ ។ ជួនជាសម័យនោះកបិលយក្ខរាជព្រះចៅក្រុងពារាណសី ចេញពីរាជធានីចូលទៅក្នុងព្រៃ ដើម្បីបាញ់ម្រឹគទ្រង់បានឃើញសុវណ្ណសាមនៅកណ្តាលហ្វូងម្រឹគដូច្នោះ ក៏លើកធ្នូបាញ់ទៅត្រូវកណ្តៀតក្អម ។ សុវណ្ណសាមក៏ដួលដេកលើគំនរខ្សាច់នាមាត់ស្ទឹងនោះស្រែកយំរៀបរាប់អាឡោះអាល័យមាតាបិតា ។ បិលយក្ខរាជឮទំនួញដូច្នោះហើយមានចិត្តអាណិតអាសូរស្ទើរធ្លាយឱរា ទើបស្ទុះចូលទៅដកព្រួញហើយលើកដាក់លើភ្លៅនិយាយសូមទោសថាកំហុសទាំងប៉ុន្មានខ្ញុំទទួលទាំងអស់ ខ្ញុំរ៉ាប់បំរើមាតាបិតាអ្នកឱ្យដូចជាអ្នកដែលធ្លាប់បំរើរៀងមកទើបសួរថា មាតាបិតាអ្នកនៅក្នុងទីណា ? សុវណ្ណសាមគ្រាន់តែប្រាប់ហើយក៏ដាច់ខ្យល់ស្លាប់ក្នុងទីនោះទៅ ។ បិលយក្ខរាជក៏យាងទៅអាស្រមតាបសទាំងពីរថា: សុវណ្ណសាមត្រូវសរស្លាប់ទៅហើយខ្ញុំមកបំរើជំនួស ។ តាបសទាំងពីរអង្គគ្រាន់តែឮដូច្នោះក៏យំសោកដួលដេកលើផែនដី បិលយក្ខរាជលើកឡើងឱ្យឈរ ហើយដឹកដៃទៅបង្ហាញទីកន្លែងដែលសុវណ្ណសាមដួលដេកនោះ ។ លុះ

តាបសទាំងពីរទៅដល់លួកដៃបបោសអង្អែល ហើយធ្វើសច្ចាធិដ្ឋានថា :

**យេន សច្ចេន យំ សាមោ ធម្មចារី បុរេ អហុ**

**ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ**

សេចក្តីថា : សាមបុត្ររបស់យើងនេះ ធ្លាប់ប្រព្រឹត្តធម៌ដ៏ប្រសើរមក ជាប់មិនដាច់ដោយសច្ចវាចាឯណា សច្ចវាចានោះ សូមឱ្យពិសសាបសូន្យជ្រះស្រឡះចេញពីសាមជាបុត្ររបស់យើង! ។

ឱជារសរបស់សច្ចវាចា ចូលទៅផ្សព្វផ្សាយក្នុងសកលកាយរបស់សុវណ្ណសាម ពិសក៏សាបសោះទៅទើបមានស្មារតីឡើង ។ សម័យបន្ទាប់នោះ ទេពធីតាដែលធ្លាប់ជាមាតាសុវណ្ណសាមពីបុព្វជាតិក៏ហោះអំពីភ្នំគន្ធមាទន៍មកពោលសច្ចវាចាថែមទៀតថា :

**បព្វត្យាហំ គន្ធមាទនេ ចិរំ រត្តំ និវាសិនី**

**នមេ បិយតរោ កោចិ អញ្ញោ សាមេហិ វិជ្ជតិ**

**ឯតេន សច្ចវជ្ជេន វិសំ សមស្ស ហញ្ញាតុ**

សេចក្តីថា: ខ្ញុំអាស្រ័យនៅលើភ្នំគន្ធមាទន៍យូរហើយ បុគ្គលណាមួយជាទីស្រឡាញ់ស្អិតស្មើនឹងសាមនេះគ្មានឡើយ ដោយអំណាចសច្ចៈវាចានេះ សូមឱ្យអោយពិសសាបសោះចេញពីកាយរបស់សាមឆាប់ៗ កុំយូរឡើយ ។

សុវណ្ណសាមបានជាសះស្បើយក្រោកឡើងភ្លាមក្នុងពេលនោះឯង តាបសទាំងពីរក៏មានភ្នែកភ្លឺស្វាងស្រឡះដូចដើមក្នុងសម័យនោះដែរ ។ ឯកបិលយក្ខ-

រាជ ក៏ប្រគល់កាយខ្លួនដល់ព្រះពោធិសត្វ ។ បានទូន្មានឱ្យធ្វើទានរក្សាសីល កាន់ទសពិធរាជធម៌ ទើបខំប្រតិបត្តិតាមដរាបដល់អស់ព្រះជន្ម ។ រឿងនេះស្ទេះទុកត្រឹមប៉ុណ្ណេះ សូមបញ្ជាក់ថា សុវណ្ណសាមព្រះពោធិសត្វ ដែលត្រូវសរដួលដេកស្តូកស្តឹងសន្លប់បាត់ស្មារតី ហើយស្រាប់តែមានជីវិតរស់ឡើងវិញ និងតាបសទាំងពីរ ដែលពិសពស់ខ្វាក់ភ្នែកអស់ហើយ បែរជាភ្លឺដូចដើមវិញយ៉ាងនេះ ក៏ដោយសារតែឱជារសនៃសច្ចៈធម៌ចូលទៅផ្សព្វផ្សាយ ព្រោះហេតុចំឡែកអស្ចារ្យដូច្នេះហើយ បានជាព្រះមានព្រះភាគទ្រង់សំដែងមាននៅក្នុងគម្ពីរសំយុត្តនិកាយថា "**សច្ចំ ហវេ សាធុតរំ រសានំ**" សច្ចៈធម៌ហ្នឹងឯងជារសប្រសើរឆើត ឆ្ងាញ់ជាងរសនានា ។ ធម្មតារសទាំងឡាយលើដែនប្រឹថពីមានរសផ្លែឈើ និងមើមឈើជាដើម អាចផ្សព្វផ្សាយទំនុកបំរុងគ្រោងកាយបានតែមនុស្សរស់ ឯមនុស្សស្លាប់មិនអាចធ្វើឱ្យមានជីពជន្មបានឡើយមានតែរសរបស់សច្ចៈធម៌ទើបប្រសើរវិសេស អាចធ្វើមនុស្សស្លាប់ហើយឱ្យរស់វិញបាន ដូចរឿងសុវណ្ណសាមនេះជាភស្តុតាងស្រាប់ ន័យនេះសមនឹងបទសុភាសិតមួយទៀតថា:

**យេ កេចិមេ អត្ថិ រសា បថព្យា**
**សច្ចំ តេសំ សាធុតរំ រសានំ ។**

សេចក្តីថា : រសអ្វីមួយមាននៅលើផែនប្រឹថពី ដែលគេត្រូវការទំពារស៊ីមានរសដើម និងរសមើមជាដើម រសគឺសច្ចៈនេះ ឆ្ងាញ់វិសេសឆើតជាងរសទាំងនោះ ។

ម្យ៉ាងវិញទៀត សច្ចៈធម៌នេះ អាចបង្អុរនូវទឹកឱ្យធ្លាក់ចុះពីអាកាសបាន ដូចមានបទសុភាសិតថា: **"សច្ចេន ទេវោ ថនយំ បវស្សតិ"** ភ្លៀងបង្អុរទឹកចុះមានបានដោយសច្ចៈធម៌ ។ សូមនាំនិទានជាតកមួយទៀតមកប្រៀបផ្ទឹមនឹងសុភាសិតនេះ ដើម្បីឱ្យជាក់ច្បាស់និទាននោះថា:

ក្នុងកាលយូរហើយ ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូរបស់យើងទ្រង់សោយព្រះជាតិជាស្តេចត្រីរស់ស្ថិតនៅក្នុងស្រះមួយនាវស្សបុរី ។ កាលនោះក្នុងវស្សបុរីទាំងមូល គ្មានភ្លៀងបង្អុរចុះសោះ រាំងអស់កាលដ៏យូរទឹកក្នុងត្រពាំងបឹងបួរីងខះអស់ ។ ឯស្រះដែលស្តេចត្រីរស់នៅនោះក៏រីងខះដែរនៅសល់តែភក់ពេលនោះពួកក្អែក ត្មាត តាដក់ ខ្លែង កុកទាំងឡាយចុះទៅចាប់ចឹកស៊ីត្រីក្នុងស្រះនោះតែរាល់ៗ ថ្ងៃ ចំណែកខាងស្តេចត្រីរស់ និងត្រីធំៗ ទាំងឡាយនាំគ្នាត្បូលមុចទៅក្នុងភក់ ។ ថ្ងៃមួយស្តេចត្រីរស់បាននិយាយនឹងត្រីទាំងឡាយថា: យើងតាំងតែមកចាប់កំណើតកើតជាត្រីនេះពុំដែលបៀតបៀនសត្វម្តងណាឡើយ យើងទាំងឡាយពុំគួរវេទនាយ៉ាងនេះសោះ ទើបស្តេចត្រីរស់ធ្វើសច្ចាធិដ្ឋានថា:

**ឯចំ បហិន្និតំ លោកេ រតនត្តយមុត្តមំ**

**ឯតេន សច្ចវជ្ជេន សម្មា ទេវោ បវស្សតុ**

សេចក្តីថា: ក្នុងលោកមានតែព្រះរតនត្រ័យជាវត្ថុ ដ៏ឧត្តមមានឫទ្ធិច្រើន បើមានយ៉ាងនេះមែន ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ចូរទេវតាបង្អុរភ្លៀងឱ្យធ្លាក់ចុះមកដោយប្រពៃ ។

ក្នុងពេលនោះបានប្រកាសចំពោះមហាមេឃទៀតថា :

**អភិត្ថនយ បជ្ជុណ្ណ និធឹ កាកស្ស នាសយ**

**កាកំ សោកាយ រន្ធេហិ មច្ឆេ សោកា បមោចយ**

**មយា កតេន សច្ចេន បជ្ជុណ្ណោ អភិវិស្សតុ**

**ផលំ និន្នញ្ញា ប្ញុវន្តោ ខណេន អភិវស្សតុ !**

សេចក្ដីថាៈ នៃមហាមេឃ! អ្នកចូរគ្រហឹមគម្រាម ចូរអ្នកញុំាងកំណប់របស់ក្អែកឱ្យវិនាស ញុំាងក្អែកឱ្យក្ដៅក្រហាយដោយសេចក្ដីសោកស្ដាយហើយធ្វើហ្វូងត្រីទាំងឡាយឱ្យរួចស្រឡះចាកសេចក្ដីសោកវិញ ។ ដោយសច្ចៈដែលយើងបានធ្វើហើយចូរមហាមេឃបង្អុរភ្លៀងឱ្យធ្លាក់ចុះមកឱ្យពេញទីទួលទីទាបចូរបង្អុរភ្លៀងឱ្យធ្លាក់ចុះមកមួយរំពេចកុំបីយឺតយូរឡើយ ។

**តស្មិំ ខណេ** ក្នុងមួយរំពេចនោះក៏ក្ដៅដល់អស្នារបស់ស្ដេចអមរន្រ្ទាធិរាជ ៗ ជ្រាបហេតុចំឡែកអស្ចារ្យដូច្នោះហើយប្រើវលាហកទេវបុត្រឱ្យឆាប់មកបង្អុរភ្លៀង វលាហកទេវបុត្រនោះក៏ញុំាងមហាមេឃទាំងមូលឱ្យគ្រហឹមគំទរគគ្រុំគគ្រេង ផ្គររន្ទះពពកខ្មៅដេរដាសពាសពេញផ្ទៃអាកាស មានខ្យល់ព្យុះបក់បោកញាប់ញ័រប្រឹថពី ភ្លៀងក៏ធ្លាក់ចុះមកជាខ្លាំងលិចទីទួលទីទំនាបអស់ឥតសល់ ។ ពួកក្អែកត្មាតតាដល់កុកទាំងឡាយក៏ភិតភ័យរត់បាត់បង់អស់ទៅ ស្ដេចត្រីរស់ព្រមទាំងត្រីជាបរិវារ បាននៅក្នុងស្រះនោះជាសុខក្សេមក្សាន្តតាំងពីពេលនោះមក ។

សូមបញ្ជាក់ឱ្យចែងច្បាស់ថាៈ ស្ដេចត្រីរស់ ដែលអាចធ្វើមហាមេឃឱ្យ

ញាប់ញ័រ ញុាំងទឹកឱ្យធ្លាក់ចុះពីអាកាសមកបានក៏ដោយសារតែសច្ចៈធម៌ ព្រោះហេតុនោះបានជាមានបទសុភាសិតថា "**សច្ចេន ទេវោ ថនយិ បវស្សតិ** ភ្លៀងបង្អុរទឹកចុះមកបានដោយសច្ចៈធម៌" ។

**បុច្ឆាថា:** សច្ចៈប្រែថា ពិតត្រង់ទៀតទាត់ ចុះសព្វថ្ងៃក្នុងសកលលោកគ្មានមនុស្សកាន់សច្ចៈទេឬ? បានជាមិនដែលឃើញហេតុអស្ចារ្យដូចជាន់មុន ។

**វិសជ្ជនាថា:** មានដែរក្នុងសកលលោកសព្វថ្ងៃនេះ មានគ្រប់ប្រទេសទាំងអស់គ្រាន់តែតិចច្រើនខុសគ្នាប៉ុណ្ណោះ បើអ្នកប្រទេស ខេត្ត ស្រុក ឃុំ ភូមិ សង្គម គ្រួសារណាមិនសូវមានសច្ចៈការពិតត្រង់ដល់គ្នានឹងគ្នាទេអ្នកប្រទេស ខេត្ត ស្រុកជាដើមនោះតែងតែវិនាសបែកបាក់ពួកបក្សព្រោងព្រាតប្រទេស ខេត្ត ស្រុកជាដើមនោះនឹងធ្លាក់ចុះនៅក្នុងហីនភាពទាបទាសដោយពិតប្រាកដ ។ ម្យ៉ាងទៀតបានជាមិនអស្ចារ្យដូចជាន់មុននោះ ព្រោះក្នុងសកលលោកសព្វថ្ងៃនេះមនុស្សទាំងឡាយមានធម្មសញ្ញាខ្សោយជាងសម័យមុន ៧ ឬ ៨ ក្នុង ១០ បានជាមិនអស្ចារ្យដូចជាន់មុន ។ ឧបមាដូចប្រទីបបើមានប្រេងធំ អុចភ្លើងទៅ មានពន្លឺក៏ធំ បើប្រេងតូចមានពន្លឺក៏តូច បើគ្មានប្រេងសោះនោះបានអ្វីនឹងអុចបើមិនបានអុចហើយមានពន្លឺពីណា ? ។

**២. ខន្តិ** សេចក្ដីអត់ធន់ ទុកជាចន្ទល់ទី ២ សម្រាប់ទល់ទ្រស្ទួយសត្វឱ្យមានមុខឆ្ពោះទៅរកអរិយធម៌ ខន្តីប្រែថាសេចក្ដីអត់ ជាគូនឹងតីតិក្ខា ប្រែថាសេចក្ដីធន់ សព្វទាំងពីរនេះមានសេចក្ដីជាមួយគ្នា ទើបរួមចូលគ្នាហៅសេចក្ដី

អត់ធន់សេចក្តីអត់ធន់នេះលោកចែកចេញជាបីយ៉ាងគឺ :

១) អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតលោភៈ

២) អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតទោសៈ

៣) អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតមោហៈ ។

ឯការអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតលោភៈនោះបានខាងការអត់ទ្រាំនឹងចំណង់ផ្សេងៗ ដែលកើតឡើងក្នុងទ្វារទាំង ៦ ។ ពាក្យថាអត់ទ្រាំគឺមិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬតាមសេចក្តីស្រេកឃ្លាននោះៗ ។ បុគ្គលចំពូកខ្លះ ព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ឬសេចក្តីស្រេកឃ្លាន បានជាហ៊ានលួចឆក់ដណ្តើមបំបាត់ប្រវ័ញ្ចន៍ទ្រព្យសម្បត្តិរបស់អ្នកដទៃ កាលបើប្រព្រឹត្តដូច្នោះ រមែងជួបប្រទះនឹងសេចក្តីទុក្ខព្រួយដែលជាផលរបស់ទុច្ចរិតនោះៗ មានត្រូវទោសជាប់គុកច្រវាក់ជាដើម ។ បុគ្គលណាជាមនុស្ស មិនសូវរវះរវាមពេកចេះអត់ទ្រាំបានបុគ្គលនោះឯងតែងប្រកបដោយសុខភាពនឹងអនាម័យដ៏ល្អ ។ ខន្តីសេចក្តីអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតលោភៈ សូម្បីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតរាគៈ ក៏គួរសង្គ្រោះចូលក្នុងខន្តីនេះដែរ ។ ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតទោសៈនោះ បានខាងសេចក្តីអត់ធន់នឹងពាក្យបរប្បវាទ ដែលបុគ្គលដទៃស្តីថា រិះគន់ឬត្មះតិះដៀល ឬអត់ធន់នឹងអំពើដែលបុគ្គលដទៃបៀតបៀនជាហេតុឱ្យកើតទោសៈ ។ ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះដែលថាមិនឱ្យគេស្តីថា មិនឱ្យគេរិះគន់នោះគ្មានទេអម្បាលព្រះអាទិត្យ ព្រះចន្ទ្រដែល

ឆ្លុះបំភ្លឺលោកជាប្រក្រតី ម្ដេចគង់មានគេតិះដៀលខ្លះដែរ ចំណង់បើមនុស្សក្នុងលោកនឹងរកនរណាឱ្យជាមនុស្សឥតគេតិះដៀលនោះមិនមានឡើយ ទុកជាព្រះសាស្ដាបរមគ្រូជាម្ចាស់ ដែលប្រកបដោយមហាករុណាទិគុណ ក៏គង់មានគេតិះដៀលខ្លះដែរ បើយល់ជាក់យ៉ាងនេះហើយ គួរឱ្យមានខន្ដីអត់ធន់កុំក្រោធខឹង ។ បោរាណាចារ្យទាំងឡាយ លោកសំដែងប្រាប់ឧបាយ គឺយោបល់ជាគ្រឿងរំលត់សេចក្ដីក្រោធខឹងថាៈ "បើទុកជាមានភ្នែកភ្លឺក៏ត្រូវធ្វើដូចជាងងឹត មានត្រចៀកស្ដាប់ឮពិត ក៏ត្រូវធ្វើដូចជាថ្លង់" ដូច្នេះទើបអត់ធន់សេចក្ដីក្រោធខឹងនោះបាន ប្រសិនបើធ្វើជាមនុស្សភ្នែកទិព្វត្រចៀកទិព្វចេះតែឃើញ ចេះតែឮ ហើយនៅជាបុថុជ្ជនចិត្តស្រាលផង ក៏នឹងរក្សាខន្ដីសេចក្ដីអត់ធន់នោះបានដោយកម្រណាស់ ។

ឯការអត់ធន់ចំពោះសេចក្ដីទុក្ខដែលជាហេតុឱ្យកើតមោហៈនោះបានខាងសេចក្ដីអត់ធន់នឹងទុក្ខវេទនាផ្សេងៗ ដែលកើតឡើងក្នុងកាយនឹងចិត្តមិនលុះក្នុងអំណាចទុក្ខវេទនា ហើយទៅប្រព្រឹត្តទុច្ចរិតឡើយ ។ សូម្បីការដែលអត់ទ្រាំនឹងទុក្ខវេទនាក្នុងវេលាឈឺថ្កាត់នោះសោត គឺជាហេតុជួយឧបត្ថម្ភឱ្យមានសតិសម្បជញ្ញៈ គឺសេចក្ដីភ្ញាក់នឹងសេចក្ដីដឹងខ្លួនដែលជាគុណវិសេសគួរឱ្យមានគ្រប់កាលទាំងពួង ពុំនោះសោតក្នុងវេលាមានព្យាធិដែលជាហេតុឱ្យដល់មរណៈ ក៏ត្រូវតែមានខន្ដីយ៉ាងមាំមួនខានពុំបានឡើយ ។ ឧបាយដែលនឹងឱ្យកើតខន្ដីក្នុងវេលានោះ គឺត្រូវគិតឱ្យឃើញតាមសេចក្ដីពិតថា ព្យាធិនឹងមរណៈនោះជាទុក្ខដែលសត្វទាំងឡាយត្រូវតែជួបប្រទះរាល់ៗ រូបគេចមិនរួចឡើយ ក្នុងអភិណ្ហ-

បច្ចវេក្ខណៈ ដែលព្រះអរហន្តសម្មាសម្ពុទ្ធទ្រង់ប្រដៅឱ្យនឹករំពឹងជារឿយៗ ថា "**ព្យាធិ ធម្មោម្ហិ ព្យាធឹ អនតីតោ** អាត្មាអញមានជម្ងឺដម្កាត់ជាធម្មតា នឹងជៀសវាងជម្ងឺដម្កាត់មិនបានឡើយ" ដូច្នេះនោះក៏គប្បីឱ្យប្រុងខ្លួនអំពីកាលដែលនៅជានៅឡើយ បើចាំទៅនឹករំពឹងក្នុងពេលដែលជម្ងឺដម្កាត់មកដល់តែម្តង ក៏មុខជាកម្រនឹងរកបាន ព្រោះវេលាដែលឈឺនោះឯងតែងមានទុក្ខព្រួយលំបាកច្រើនយ៉ាងណាស់ កាលបើអត់ទ្រាំទុក្ខវេទនាមិនបានសតិសម្បជញ្ញៈក៏នឹងទ្រេតទ្រោតមិនតាំងនៅខ្ជាប់ឡើយ ដូចជនចំពូកខ្លះដែលមិនបានហាត់ចិត្តទុកអំពីកាលនៅជានោះលុះវេលាដែលមានជម្ងឺយ៉ាងធ្ងន់មកដល់ក៏ច្រើនតែមានចិត្តរវើរវាយផ្សេងៗ ដរាបដល់ធ្វើអំពើទុច្ចរិតមានសម្លាប់សត្វជាដើម ដើម្បីបូជាគ្រោះដោយចង់រស់តែខ្លួនឯង មិនគិតអាណិតសត្វដទៃក៏មាន ។ ព្រោះហេតុដូច្នោះការដែលបង្ហាត់ចិត្តបង្ហាត់ស្មារតី ដើម្បីឱ្យកើតខន្តីនោះ ជាកិច្ចដែលយើងត្រូវការគ្រប់ៗ ប្រាណសម្រាប់តយុទ្ធនឹងសត្រូវ គឺព្យាធិទុក្ខក្នុងវេលាដែលជិតនឹងដល់មរណៈទុក្ខនោះ ។ ចំណែកអ្នកដែលមានប្រាថ្នារៀនរកនូវភោគទ្រព្យនិងវិទ្យាសាស្ត្រមានអក្សរសាស្ត្រ ក្សេត្រសាស្ត្រ នឹងពាណិជ្ជកម្ម កសិកម្មជាដើម បើមានខន្តីអត់ធន់នូវការស្រេកឃ្លានមានក្រ ទុក្ខក្តៅត្រជាក់ជាដើមហើយ វិជ្ជានឹងភោគទ្រព្យក៏រមែងសម្រេចដល់បុគ្គលនោះដោយមុហុត្តភាព បុគ្គលនោះនឹងធ្វើខ្លួនឱ្យទៅជាមនុស្សចំរើនលោកបាន ។

ម្យ៉ាងទៀតអ្នកដែលមានខន្តី រមែងជាទីប្រឹក្សានៃទេវតានិងមនុស្សទាំងឡាយសមនឹងពុទ្ធភាសិតថា :

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**

**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ**

អ្នកមានខន្តីជាអ្នកមានមេត្តា ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកមានខន្តី រមែងជាទីស្រឡាញ់ជាទីគាប់ចិត្តនៃទេវតានិងមនុស្សទាំងឡាយ ។

ម្យ៉ាងទៀតខន្តីនេះទុកដូចជាភាជន៍សំរាបដិកល់នូវគុណធម៌ គឺសីលនិងសមាធិ ឱ្យស្ថិតនៅខ្ជាប់កុំឱ្យរាត់រាយខ្ចាត់ខ្ចាយ ឬទុកដូចជាពូជរបស់កុសលធម៌ទាំងពួង ព្រោះមានពុទ្ធភាសិតថា:

**សីលសមាធិគុណានំ ខន្តិ បធានការណំ**

**សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិតេ ។**

ខន្តី ជាហេតុជាទីតាំងនៃគុណ គឺសីលនឹងសមាធិទាំងឡាយធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចំរើនដោយសេចក្តីអត់ធន់មែនពិត ។

ម្យ៉ាងទៀតខន្តីនេះទុកជាអាវុធដ៏មុះមុតសំរាប់កាត់ផ្តាច់នូវឫសគល់នៃបាបទាំងឡាយ ឬសំរាប់ជីកគាស់រំលើងនូវឫសគល់នៃទោសទាំងឡាយមានការឈ្លោះប្រកែកជាដើម សមនឹងពុទ្ធភាសិតថា:

**គេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**

**គរហកលហាទីនំ មូលំ ខនតិ ខន្តិកោ ។**

ខន្តីតែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់

ធន់ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែកជាដើម ។

ម្យ៉ាងទៀតខន្តីនេះទុកជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ជាភ្លើងសំរាប់ដុតកំលោចនូវបាប ជាពលីរបស់ធម្មចារីទាំងឡាយ នឹងជាប្រឡាយសំរាប់បង្ហូរមកនូវប្រយោជន៍នឹងសេចក្តីសុខ ព្រោះពុទ្ធភាសិតថា:

**ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ**

**ខន្តិ ពលំ វយតីនំ ខន្តិ ហិតសុខាវហា ឬ**

ខន្តីជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ខន្តីជាគ្រឿងដុតនូវបាបរបស់អ្នកប្រព្រឹត្តធម៌ ខន្តីជាគុណជាតិនាំមកនូវប្រយោជន៍នឹងសេចក្តីសុខ ។

ម្យ៉ាងទៀតខន្តីនេះ បើមានក្នុងបុគ្គលណាហើយបុគ្គលនោះឈ្មោះថាជាអ្នកដឹកជញ្ជូននាំមកនូវប្រយោជន៍ដើម្បីខ្លួនផង ឱ្យដល់បុគ្គលដទៃផងទាំងឈ្មោះថាជាអ្នកបានដើរក្នុងផ្លូវជាទីទៅកាន់ស្ថានសួគ៌ នឹងព្រះនិព្វានសមនឹងពុទ្ធភាសិតថា:

**អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ**

**សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ ៤**

អ្នកមានខន្តី ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកមានខន្តីជាអ្នកបានឡើងកាន់ផ្លូវជាទីទៅស្ថានសួគ៌នឹងព្រះនិព្វាន។

ម្យ៉ាងវិញទៀតអ្នកមានខន្តី ឈ្មោះថាជាអ្នកប្រតិបត្តិតាមឱវាទរបស់

ព្រះសម្ពុទ្ធ ជាអ្នកបានបូជានូវព្រះសម្ពុទ្ធ ដោយការបូជាដ៏ខ្ពង់ខ្ពស់ព្រោះមានពុទ្ធភាសិតថា:

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ**

**បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ ។**

អ្នកមានខន្តី ឈ្មោះថាធ្វើតាមនូវព្រះពុទ្ធដីកាជាឱវាទរបស់ព្រះសាស្តា មែនអ្នកមានខន្តី ឈ្មោះថាបានបូជានូវព្រះជិនស្រីដោយការបូជាដ៏ឧត្តម ។

ឯពាក្យថាខន្តីនេះ សំដៅយកត្រង់ការអត់ធន់នូវសម្ផស្សរបោម មូលខ្យល់ កំដៅថ្ងៃ ពស់តូច ពស់ធំ សេចក្តីស្រេកឃ្លាន នឹងពាក្យអាក្រក់របស់បុគ្គលដទៃជាដើម កាលបើហេតុទាំងនេះកើតមានឡើង ចេះអត់ធន់បានមិនញាប់ញ័រមិនបណ្តោយឱ្យខូចប្រយោជន៍ដោយសារតែហេតុទាំងនោះ ។

អ្នកប្រាជ្ញទាំងឡាយតែងសរសើរនូវបុគ្គលដែលចេះអត់ធន់ គឺចេះប្រើខន្តីតាមលំអានរបស់បណ្ឌិត តាមធម្មតាបណ្ឌិត បើបុគ្គលណាតូចទាបថោកថយជាង ទោះបីបុគ្គលនោះពោលពាក្យអាក្រក់យ៉ាងណាទៅរក ក៏ចេះអត់សង្កត់ចិត្តបានមិនរំភើបញាប់ញ័រឡើយ ដោយមានគំនិតថា: មនុស្សល្ងង់ច្រើនប្រើពាក្យសំដីអសប្បុរស ។ ន័យនេះសមនឹងភាសិតដែលសរភង្គតាបសបានពោលទុកថា:

**ភយា ហិ សេដ្ឋស្ស វចោ ខមេថ**

**សារម្ភហេតុ បន សាទិសស្ស**

## យោចីធ ហីនស្ស វចោ ខមេថ
## ឯតំ ខន្តឹ ឧត្តមមាហុ សន្តោ ។

សេចក្តីថា: ការអត់ធន់នូវពាក្យពោលរបស់បុគ្គលដែលប្រសើរជាងខ្លួនដោយជាតិនិងគោត្តជាដើមព្រោះខ្លាចគេ ១ ការអត់ធន់នូវពាក្យអាក្រក់របស់បុគ្គលដែលស្មើនឹងខ្លួន ព្រោះឃើញទោសនៃការប្រណាំងប្រជែង ១ នេះមិនហៅថាអធិវាសនក្ខន្តីទេ[១] ។ លុះតែបុគ្គលណាក្នុងលោកនេះ ខំអត់ធន់នូវពាក្យពោលរបស់បុគ្គលដែលថោកទាបជាងខ្លួនដោយជាតិជាដើម សប្បុរសទាំងឡាយតែងពោលសរសើរនូវការអត់ធន់នោះថាជាខន្តីដ៏ឧត្តម ។

ខន្តីនេះព្រះសម្ពុទ្ធចាត់ឱ្យឈ្មោះថាបរមធម៌ក្នុងលោកិយ ឯព្រះនិព្វានជាបរមធម៌ក្នុងលោកុត្តរៈ ។

ខន្តីនោះ បានជាហៅថាបរមធម៌ក្នុងលោកិយព្រោះវិសេសបំផុតខាងការដុតកំដៅបាបធម៌ទាំងឡាយមានទោសៈសេចក្តីប្រទូស្ត កោធៈសេចក្តីក្រោធ ព្យាបាទៈ ការបំផ្លាញគេឱ្យវិនាស វិហឹសា ការបៀតបៀនគេ អរតិ ការឈ្នានិះគេ បដិឃៈ សេចក្តីថ្នាំងថ្នាក់ជាដើមដែលជាសាខារបស់ទោសៈ ឱ្យទ្រុឌទ្រោមរីងស្ងួតទៅបាន ។ ធម្មតាទោសៈដែលចំរើនធំថ្លោសឡើងបាន ក៏អាស្រ័យសេចក្តីមិនអត់ធន់ ដូចជាពួកភិក្ខុក្នុងដែនកោសម្ពីដែលអាស្រ័យហេតុបន្តិចបន្តួចសព្វបើទឹកដែលសល់អំពីការជំរះលាមកប៉ុណ្ណោះមិនខំអត់ធន់ ផ្តួចផ្តើមឱ្យកើត

១- ការអត់ធន់ចំពោះហេតុដែលបណ្តាលឱ្យកើតទោសៈហៅថា អធិវាសនខន្តី

ជាវិវាទវាលធំធាត់ឡើងដរាបដល់បែកសាមគ្គី បើប្រសិនជាខាងណាម្ខាង អត់ធន់បានរឿងរ៉ាវនោះកើតឡើងពុំបានឡើយ ។ ខន្តីនេះមិនមែនមានគុណវិសេសចំពោះតែខ្លួនទេ រមែងមានគុណវិសេសដល់បុគ្គលដទៃផង ។

ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធទ្រង់សរសើរថាជាបរមធម៌ក្នុងលោកិយ ដូចមានពុទ្ធភាសិតក្នុងគម្ពីរមហាបដ្ឋានត្រង់សរូបចតុវីសតិបច្ចយវារៈថាៈ

**ខន្តិ ហិ បរមំ លោកេ ខន្តិ លោកេ បធានតា**

**ខន្តិយា វិជ្ជមានាយ សព្វបុញ្ញញ្ញ វិជ្ជតិ ។**

សេចក្តីថាៈ ខន្តីជាធម៌ដ៏ឧត្តមក្នុងលោក ខន្តីធម៌ជាប្រធានក្នុងលោក ក៏បុណ្យទាំងអស់រមែងមានក្នុងខន្តី ។

បើប្រាសចាកខន្តីហើយរមែងជួបប្រទះតែនឹងសេចក្តីទុក្ខលំបាកក្រីក្រ ថោកទាបជានិច្ច ។

ខន្តីនេះគួរតែឱ្យមានគ្រប់ពេលវេលា សូម្បីក្នុងហេតុបន្តិចបន្តួចក៏គួរតែឱ្យមាន បើមិនមានក្នុងវេលាណាមួយហើយ រមែងជួបប្រទះនឹងសេចក្តីព្រួយលំបាកថោកទាបអាប់សិរីសួស្តីពុំខាន ដូចមានរឿងមួយក្នុងគម្ពីរសំស្ក្រឹតជំណាលថាៈ

ក្នុងសម័យមួយ មានបុរសម្នាក់ទើបនឹងការហើយថ្មីៗ បាននាំភរិយាទៅលេងផ្ទះម្តាយក្មេកឪពុកក្មេក លុះទៅដល់កាលណា ម្តាយក្មេកឪពុកក្មេក ក៏មានសេចក្តីត្រេកអរនឹងកូនប្រសារនោះឥតឧបមា ឪពុកក្មេកបានរៀបចំអាសនៈឱ្យកូនប្រសារនោះអង្គុយ ឯម្តាយក្មេកក៏ខំម៉ីម្ងាទៅចាត់ចែងចំអិនអាហារ ៤

មុខដែលប្រកបដោយរស ៦ ប្រការ ជាអាហារផ្សំដោយរសផ្សេងៗ មានអាហារឈ្មោះបបរ្យដះជាដើម ដើម្បីឱ្យកូនប្រសារនោះបរិភោគ ។ លុះចំអិនរួចហើយ ក៏ដួសដោះដាក់ចានដម្កល់លើស្ពក លើកយកទៅឱ្យកូនប្រសារនោះបរិភោគ ក្នុងពេលដែលកូនប្រសារកំពុងបរិភោគ ម្តាយក្មេកបានរោយលំអិតល្ងឱ្យ ។ ឯកូនប្រសារនោះជាមនុស្សមានសេចក្តីខ្មាស់អៀនច្រើន ក៏និយាយឃាត់ម្តាយក្មេកថាល្មមហើយៗ ម្តាយក្មេករោយឱ្យតែបន្តិចក៏ដើរចេញទៅ ។ គ្រានោះកូនប្រសាបានភ្លក់មើលលំអិតល្ងដែលម្តាយក្មេកបានរោយឱ្យ។ ឯលំអិតល្ងនោះមានរសឆ្ងាញ់យ៉ាងវិសេសជាហេតុបណ្តាលឱ្យកូនប្រសាមានចំណង់ក្នុងសំអិតល្ងនោះក្រៃពេក ប៉ុន្តែមិនអាចហ៊ានលូកដៃទៅចាប់លំអិតល្ងនោះឡើយព្រោះជាអ្នកមានសេចក្តីខ្មាស់អៀនច្រើន ។ លុះបរិភោគរួចហើយ ក៏បានឃើញត្បាល់នឹងអង្រែដែលម្តាយក្មេកបុកលំអិតល្ងនៅក្បែរជញ្ជាំង ។

ពេលនោះសេចក្តីចំណង់ក៏បណ្តាលឡើងម្តងទៀតជាខ្លាំង ព្រោះបានឃើញលំអិតល្ងជាប់នៅក្នុងបាតត្បាល់ត្រង់កន្លែងដែលខ្វះៗ បន្តិចៗ ។ ឯកូនប្រសានោះជាមនុស្សគ្មានខន្តីពុំអាចអត់ទ្រាំនឹងសេចក្តីចំណង់នោះបាន សេចក្តីចំណង់ក៏កាន់តែបណ្តាលខ្លាំងឡើងៗ ដរាបដល់ស្រក់ទឹកមាត់ ជួនជាវេលានោះជាពេលស្ងាត់ល្អ ក៏ក្រោកដើរទៅឱនក្បាលបញ្ចូលទៅក្នុងត្បាល់នោះដើម្បីលិទ្ធនូវលំអិតល្ង ។ ឱជារសនៃល្ងអាចបំភាន់ស្មារតីរបស់កូនប្រសានោះ ឱ្យភ្លេចគិតពីគ្រោះថ្នាក់ផ្សេងៗ ក៏ចេះតែខំរុលក្បាលទៅក្នុងត្បាល់នោះបន្តិចម្តងៗ លុះលិទ្ធរួចហើយ ក្បាលក៏ជាប់ណែននៅក្នុងត្បាល់នោះ ទោះបីខំរើដកយ៉ាងណាក៏ពុំ

អាចធ្វើក្បាលឱ្យផុតពីបាតត្បាល់បានឡើយ ។ គួរឱ្យសង្វេគណាស់ កូនប្រសារនោះធ្វើដូចម្តេចទៅហ្ន៎ ។

លំដាប់នោះជនទាំងឡាយមានម្តាយក្មេកឪពុកក្មេកជាដើម បានឃើញដូច្នោះហើយ ក៏នាំគ្នាខំទាញយកកូនប្រសារនោះអំពីត្បាល់បានមកដោយលំបាក ។ កូនប្រសារនោះបានរួចផុតពីត្បាល់ហើយក៏ដល់នូវសេចក្តីថោកទាបអាប់សិរីសួស្តី ខ្មាសអៀនជនទាំងឡាយ មានម្តាយក្មេងឪពុកក្មេកជាដើមនោះឥតឧបមា ។

ដែលដល់នូវហេតុចំឡែកយ៉ាងនេះ ក៏ព្រោះតែគ្មានខន្តីអត់ធន់នូវចំណង់ក្នុងលំអិតល្ហប៉ុណ្ណោះ ។

ព្រោះហេតុនោះលោកអ្នកសប្បុរសទាំងឡាយ គួរខំចំរើនខន្តីធម៌ឱ្យមានឡើងគ្រប់ៗគ្នា ។

ខន្តីធម៌នេះបើបានស្ថិតនៅក្នុងសន្តានរបស់សត្វណាហើយ អាចទាញដួងសន្តានរបស់សត្វនោះឱ្យផុតពីទុក្ខភាព ទៅដម្កល់លើគំនរសុខភាពបានដូចមានរឿងមួយក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់អនុស្សតិនិទ្ទេស្សថា:

កាលដែលព្រះមានព្រះភាគទ្រង់ប្រទានធម្មទេសនា ដល់បរិស័ទអ្នកនៅក្នុងនគរចម្បា (១) ក្បែរមាត់ស្រះបោក្ខរណីឈ្មោះគគ្គរា ។ គ្រានោះមានសត្វកង្កែបមួយកំពុងសម្ងំស្តាប់ធម៌ទេសនា ស្រាប់តែមានអ្នកគង្វាលគោម្នាក់ ដើមមកឈរច្រត់ដំបងសង្កត់លើក្បាល កង្កែបនោះខំទ្រាំអត់នឹងជម្ងឺប្រឹងតែស្តាប់

១-ប្រហែលជាសំដែង សាណទណ្ឌសូត្រ ដែលមានក្នុងគម្ពីរទីឃៈនិកាយសិលក្ខន្ធវគ្គ ។

ធម៌ មិនលះបង់សព្វព្រះសទ្ធម្ម ក៏ធ្វើមរណកាលក្នុងខណៈនោះទៅ ទៅកើតក្នុងស្ថានតាវត្តឹង្សបានឈ្មោះថា "មណ្ឌូកទេវបុត្រ" នៅក្នុងវិមានមាសកំពស់ ១២ យោជន៍ ហាក់ដូចជាភ្ញាក់ពីដេកហើយស្រាប់តែឃើញស្រីទេពអប្សរចោមរោមជាបរិវារក៏នឹកថា: យីអើ! គួរឱ្យឆ្ងល់ពេកណាស់ ហេតុអ្វីអេះ! អញលោតែបានមកប្រតិស្ឋក្នុងទីនេះ រំពឹងទៅឃើញបុញ្ញាកម្មដែលខ្លួនខំអត់ទ្រាំនឹងជម្ងឺប្រឹងផ្ចង់ស្មារតីមិនឱ្យឃ្លាតពីសព្វព្រះធម៌ទេសនារបស់ព្រះពុទ្ធ ទើបហោះចុះពីទេវលោកព្រមទាំងវិមានមកថ្វាយបង្គំព្រះសម្ពុទ្ធជាបរមគ្រូ ។ គ្រានោះព្រះមានព្រះភាគទ្រង់មានពុទ្ធតម្រាស់ត្រាស់សួរថា:

**កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ**

**អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា ។**

អ្នកណាហ្ន៎! មានឫទ្ធិ មានយសរុងរឿង មានរស្មីចែងចាំងញ៉ាំងទិសទាំងពួងឱ្យភ្លឺស្វាង មកសំពះ បាទតថាគត ?

ទេវបុត្រក្រាបទូលថា:

**មណ្ឌូកោហំ បុរេ អាសឹ ឧទកេ វារិគោចរេ**

**តវ ធម្មំ សុណន្តស្ស អវធិ វច្ឆបាលកោ ។**

ខ្ញុំព្រះអង្គ កាលពីដើមឡើយជាសត្វកង្កែប នៅអាស្រ័យក្នុងទឹកមានវារីជាគោចរ កាលកំពុងស្តាប់ធម៌ព្រះអង្គ អ្នកគង្វាលគោសម្លាប់ខ្ញុំព្រះអង្គ ។

ព្រះមានព្រះភាគទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់ប្រទានធម៌ទេសនាសត្វទាំងឡាយ បានលុះមគ្គាភិសម័យ ចំនួន ៨ ម៉ឺន ៤ ពាន់នាក់ ។ ឯទេវបុត្រ

នោះលុះបានដល់សោតាបត្តិផលក៏ហោះទៅកាន់ទេវលោកវិញ ។ នេះជាអានិសង្សរបស់ខន្តី បញ្ជាក់សេចក្ដីថា ក្នុងពេលដែលអ្នកគង្វាលគោច្រត់លើ បើកង្កែបពុំមានការអត់ទ្រាំ បណ្ដោយឱ្យដវនចិត្ត ស្ទុះចេញពីសព្ទព្រះសទ្ធម្ម ក៏ពុំបានសម្រេចដល់ថាន: ក៏ខ្ពង់ខ្ពស់យ៉ាងនេះ [១] ។

ទី ៣ កតញ្ញូតា សេចក្ដីដឹងគុណទុកជាចន្ទល់គម្រប់បី សម្រាប់ទល់ទ្រលើកសត្វឱ្យដល់នូវអនាគតភាពដ៏ល្អ ។ កតញ្ញូតាធម៌ជាគូនឹងកតវេទិតាធម៌ គឺបើដឹងថាបុគ្គលណាមួយ មានឧបការគុណដល់ខ្លួនហើយ ត្រូវធ្វើគុណតបបុគ្គលនោះវិញ បើគ្រាន់តែដឹង១ ប៉ុណ្ណោះក៏មិនអាចញ៉ាំងប្រយោជន៍ឱ្យសម្រេចបានដូចជាដឹងថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានគុណជាអនន្តចំពោះសត្វទាំងអស់ក្នុងត្រៃភព សត្វទាំងនោះគួរតែតាំងចិត្តឱ្យស្មោះចំពោះ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យកជាទីពឹង ទីរលឹកស្មើដោយជីវិត ទាំងខំប្រតិបត្តិតាមឱវាទរបស់ព្រះពុទ្ធជាម្ចាស់ពុំប្រព្រឹត្តកន្លងដូច្នោះជាដើម ឈ្មោះថា មានកតញ្ញូកតវេទិតាធម៌ចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រមទាំងដឹងគុណចំពោះបុព្វការីទាំងឡាយមានមាតា បិតាជាដើម គឺត្រូវថែរក្សាដោយស្មោះស្ម័គ្រ ទាំងខ្លួនសោតក៏ខំប្រព្រឹត្តឱ្យល្អ កុំឱ្យលោកព្រួយចិត្តដោយសារខ្លួន បើលោកមិនទាន់មានសទ្ធា សីលៈ.ចាគៈ. បញ្ញាគប្បីឱ្យមានឡើង ។

ម្យ៉ាងទៀតក្នុងប្រទេសនីមួយ១ ពួកពលរដ្ឋទាំងឡាយត្រូវមានកតញ្ញូកតវេទិតាធម៌ចំពោះព្រះមហាក្សត្រ ស៊ូយកកម្លាំងកាយ និងកម្លាំងទ្រព្យធនធ្វើជារាជពលី ក្នុងពេលដែលកើតអសន្តិសុខម្ដង១ ក្នុងប្រទេស ហើយត្រូវស្រឡាញ់

ព្រះមហាក្សត្ររបស់ខ្លួនស្មើដោយជីវិត ត្រូវដឹងគុណពួកសេវកាមាត្យទាំងឡាយដែលបានតែងតាំងច្បាប់ឱ្យប្រតិបត្តិ ដើម្បីបានសេចក្តីសុខចម្រើន បើពួកសេវកាមាត្យទាំងនោះមានកើតអាសន្នដោយហេតុណាមួយ ត្រូវជួយដោយស្មោះស្ម័គ្រទាំងខំប្រតិបត្តិតាមច្បាប់ពុំហ៊ានប្រព្រឹត្តកន្លង គឺខំប្រតិបត្តិតាមព្រះរាជានុញ្ញាតនិងរាជបញ្ញត្តិ ដូច្នេះជាដើម ឈ្មោះថាមានកតញ្ញូកតវេទិតាធម៌ចំពោះសេវកាមាត្យ ព្រោះព្រះរាជានុញ្ញាត្តនោះ ព្រះមហាក្សត្រតែងអនុញ្ញាត និងបញ្ញត្តិអនុលោមតាមច្បាប់ដែលក្រុមសេវកាមាត្យបានប្រជុំគ្នាប្រឹក្សាហើយ ។ ឯសេវកាមាត្យត្រូវប្រកបដោយមេត្តាករុណា អាសូរប្រណីចំពោះពលរដ្ឋទាំងសកលរដ្ឋ ត្រូវកាន់សច្ចៈនិងខន្តីឱ្យខ្ជាប់កុំលះលង់ក្នុងអំណាចនៃអគតិធម៌ទាំង៤យ៉ាងមានឆន្ទាគតិជាដើម កាលបើបានស្ថិតនៅក្នុងសច្ចៈ និងខន្តីទាំងមិនក្នុងអំណាចនៃអគតិធម៌ដូច្នោះហើយ ពួកសេវកាមាត្យនោះឈ្មោះថា មានកតញ្ញូកតវេទិតាធម៌ចំពោះពលរដ្ឋទាំង សកលរដ្ឋវិញ ។

បើបុគ្គលណា បានប្រកបដោយកតញ្ញូកតវេទិតាធម៌នេះហើយ បុគ្គលនោះឈ្មោះថាបិទទ្វារទ្វារនៃអបាយភូមិទាំង ៤ មាននរកជាដើម និងបានប្រកបដោយសុខភាពអនាម័យដ៏ល្អ បើនៅក្នុងប្រទេស ខេត្ត ស្រុក ឃុំ ភូមិណា អ្នកប្រទេស ខេត្ត ស្រុក ឃុំ ភូមិនោះ តែងរាប់អានស្រឡាញ់គោរពបូជាលើកដំកើងជានិច្ច ។

បោរាណបណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម ដែលស្វែងរកគំនរសុខ

លោកមិនដែលលះបង់នូវកតញ្ញូកតវេទិតាធម៌នេះឡើយ ដូចមាននិទានមួយក្នុងគម្ពីរមង្គលត្ថទីបនី អដ្ឋកថាមង្គលសូត្រថា :

ក្នុងកាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាស្តេចត្មាត បានដម្កល់ទុកនូវមាតាបិតាដែលចាស់ជរាខ្វាក់ងងឹតក្នុងគិជ្ឈគូហា ហើយទៅស្វែងរកចំណីអាហារទាំងឡាយមានសាច់គោជាដើមយកមកចិញ្ចឹម ។ កាលនោះមានអ្នកនេសាទម្នាក់ឈ្មោះ និលិយៈ បានដាក់រាយនូវអន្ទាក់ក្នុងព្រៃស្មសាននាក្រុងពារាណសី ។ ព្រះពោធិសត្វជាប់នូវអន្ទាក់នោះហើយ ក៏មានចិត្តនឹករលឹកដល់មាតាបិតារបស់ខ្លួន ដែលចាស់ជរាខ្វាក់ងងឹត ទើបយំបំរាស់នទៀលរៀបរាប់ជាភាសាមនុស្សថា: ឱមាតាបិតាអញអើយ ទំនងជាទន្ទឹងចាំមើលផ្លូវកូនមិនដឹងជាកូនមកជាប់អន្ទាក់គេឡើយ បើដូច្នេះតើធ្វើដូចម្ដេចនឹងបានឆ្អែត ពីថ្ងៃនេះទៅជាបុគ្គលអនាថាឥតទីពឹង មុខជានឹងស្លមស្លាប់ក្នុងល្អាកភ្នំមិនខាន ។

អ្នកនេសាទឮពាក្យនោះហើយក៏និយាយថា :

**យន្នុ គិជ្ឈោ យោជនសតំ កុណបានិ អវេក្ខតិ**

**កស្មា ជាលញ្ច បាសញ្ច អាសជ្ជាបិ ន ពុជ្ឈសិ ។**

ហេតុអ្វីក៏ជាប់នូវលប់ និងអន្ទាក់ហើយ អ្នកនៅតែមិនដឹងខ្លួន ក្រែងមនុស្សទាំងឡាយតែងនិយាយថា ត្មាតអាចមើលនូវសាកសពទាំងឡាយ ដែលនៅក្នុងទី១រយយោជន៍បាន ។

ព្រះពោធិសត្វឆ្លើយតបថា:

**យទា មរាគទោ ហោតិ ឃោសោ ជីវិតសង្ខយេ**

**អថ ជាលញ្ច បាសញ្ច អាសជ្ជាបិ ន ពុជ្ឈតិ ។**

សេចក្ដីវិនាស មានក្នុងកាលណា សត្វសូម្បីជាប់នូវលប់ និងអន្ទាក់ហើយក៏ដោយ មិនអាចដឹងជាខ្លួនស្លាប់ក្នុងកាលនោះឡើយ ។

អ្នកនេសាទស្ដាប់នូវធម្មកថានោះហើយ ក៏មានចិត្តរីករាយ ទើបគិតថា "ស្ដេចត្មាតនេះជាបណ្ឌិត កាលដែលយំសោក មិនមែនយំសោកដើម្បីខ្លួនទេ ពិតជាយំសោកព្រោះតែមាតាបិតា អញមិនគួរសម្លាប់ត្មាតនេះឡើយ" ក៏ចូលទៅដោះអន្ទាក់ពីជើងត្មាតនោះដោយប្រិយចិត្ត ហើយនិយាយប្រាប់ថា:

**ភរស្សុ មាតាបិតរោ ចុន្នេ គិរីទរីសយេ**

**មយា ត្វំ សមនុញ្ញាតោ សោត្ថី បស្សាហិ ញាតកេ ។**

អ្នកខ្ញុំដោះលែងហើយ ! ចូរចិញ្ចឹមមាតាបិតាចាស់ជរា ដែលដេកនៅក្នុងព្រៃភ្នំ ចូរជួបជុំនូវញាតិទាំងឡាយដោយសួស្ដីចុះ ។

ព្រះពោធិសត្វបានរួចអំពីមរណទុក្ខហើយ ក៏ធ្វើនូវ អនុមោទនានិយាយតបវិញថា:

**ឯវំ លុទ្ទក នន្ទស្សុ សហ សព្វេហិ ញាតិភិ**

**ភរិស្សំ មាតាបិតរោ ចុន្នេ គិរីទរីសយេ ។**

ម្នាលព្រាន បើអ្នកឱ្យអភ័យដល់ខ្ញុំយ៉ាងនេះ អ្នកចូររីករាយ ជាមួយនឹងញាតិទាំងឡាយគ្រប់គ្នាចុះ ខ្ញុំនឹងចិញ្ចឹមមាតាបិតាចាស់ជរា ដែលដេកនៅ

ក្នុងញកភ្នំ ។ និយាយហើយ ក៏ពាំនូវសាច់ពេញមាត់យកទៅជូនមាតាបិតា ។ ដែលបានរួចរស់ជីវិតយ៉ាងនេះ ក៏ព្រោះតែគុណនៃកតញ្ញូកតវេទិតាធម៌ ។

ម្យ៉ាងទៀត កតញ្ញូកតវេទិតាធម៌នេះ បើបុគ្គលណាបានបំពេញឱ្យបរិបូណ៌ហើយ សូម្បីបុគ្គលនោះដល់នូវហេតុដែលត្រូវតែស្លាប់ប្រាកដក៏អាចរស់ឡើងវិញបាន ដូចមាននិទានមួយក្នុងគម្ពីរបញ្ញាសជាតកថា:

កាលដែលកន្លងទៅហើយព្រះសម្ពុទ្ធបរមគ្រូរបស់យើង កំពុងបំពេញនូវបារមីធម៌ បានទទួលបដិសន្ធិភាពក្នុងផ្ទៃនៃព្រះនាងសិរិរតនាកា ជាព្រះអគ្គមហេសី ព្រះបាទមហារថរាជ ព្រះចៅក្រុងបយរតី ។ កាលបើព្រះពោធិសត្វទ្រង់ស្ថិតនៅក្នុងគភ៌ហើយ ថ្ងៃមួយមហាមេឃក៏បណ្ដាលជាភ្លៀងធំធ្លាក់ចុះមកឥតមានដាច់គ្រាប់ឡើយ ឯទឹកភ្លៀងនោះក៏កាន់តែច្រើនឡើងៗ ជាលំដាប់រហូតដល់ទៅមានកំពស់៧ដើមត្នោតលិចភូមិស្រុកអស់ ឥតមានសល់ចំណែករលកធំៗ ក៏បោកផ្ចប់មហាជនឱ្យដល់នូវសេចក្ដីវិនាសយ៉ាងធំ ។ ឯព្រះបាទមហារថរាជ និងព្រះអគ្គមហេសីបានឡើងលើនាវា រលកក៏បក់បន្សាត់នាវានោះឱ្យអណ្ដែតត្រឡប់ត្រឡិនទៅតាមខ្សែទឹក ព្រះនាងទេវីនោះទ្រង់គភ៌បរិបូណ៌គ្រប់ខែហើយ ជាស្រីប្រកបដោយភ័យខ្លាចច្រើន ។ ចំណែកខាងរលកក៏បោកបំបែកបំបាក់នាវានោះជាពីរកំណាត់ឱ្យក្សត្រទាំងពីរព្រាត់ប្រាសគ្នាព្រះនាងទេវីអណ្ដែតទៅជាប់នឹងជើងភ្នំចន្ទបពិត ព្រះនាងក៏ឡើងទៅលើភ្នំនោះ ហាលកាយស្ងួតហើយ ទៅអង្គុយក្រោមដើមឈើ១ដោយអំណាចបុណ្យរបស់ព្រះពោធិសត្វដែលស្ថិតនៅក្នុងគភ៌ ក៏បណ្ដាលនូវហេតុនោះឱ្យដឹងដល់ព្រះឥន្ទ្រ១ ក៏ប្រើ

វិស្សកម្មទេវបុត្រ ឱ្យចុះមកនិម្មិតបណ្ណសាលា នឹងគ្រឿងបរិក្ខារគ្រប់យ៉ាងហើយ ឱ្យចារិកអក្សរនៅក្លោងទ្វារៈ

**យោ បព្វជិតុកាមោ យថាសុខំ គណ្ហតុ**

អ្នកណាត្រូវការបួស អ្នកនោះចូរកាន់យកនូវគ្រឿងបរិក្ខារនោះ តាមសេចក្ដីសប្បាយចុះ" ។

ចំណែកខាងព្រះនាងទេវីនោះសោត ក៏ផ្ចិតផ្ចង់ទៅដោយសេចក្ដីទោមនស្សតែរាល់ពេលឥតមានស្រាកស្រាន្តឡើយ ក្នុងថ្ងៃ១ព្រះនាងក៏លីលាទៅតាមមាគ៌ាបានឃើញនូវបណ្ណសាលាព្រមទាំងឃើញអក្សរនៅលើក្លោងទ្វារ នាងទតបានជ្រាបសេចក្ដីហើយ ទើបចូលទៅសំណាក់ក្នុងសាលានោះ ហើយទ្រង់ព្រះផ្នួសជាតបសិនី ។ ឯគភ៌របស់ព្រះនាងក៏រើកឡើងក្នុងវេលាថ្ងៃនោះ ដល់ពេលពាក់កណ្ដាលអាធ្រាត្រ ក៏ប្រសូត្រព្រះពោធិសត្វមក មានពណ៌ដូចជាមាសឆ្អិន ក្នុងពេលដែលប្រសូតនោះ កែវទាំងឡាយក្នុងព្រៃហិមពាន្តទាំងអស់ក៏បញ្ចេញពន្លឺភ្លឺព្រោងព្រាត ទើបព្រះនាងសន្មតនាមថ្វាយព្រះពោធិសត្វថា **រតនបជោត** ។

ក្នុងពេលក្រោយមក ព្រះនាងទេវីស្ដេចចូលទៅក្នុងព្រៃស្វែងរកផលាផល ទុកពោធិសត្វឱ្យនៅចាំសាលា ព្រះពោធិសត្វក៏ចេញពីសាលា ទៅតាមស្នាមព្រះបាទមាតា ព្រោះធ្លាប់បានឃើញព្រះមាតាទៅក្នុងពេលមុន ។ ថ្ងៃមួយនោះ ព្រះនាងទេវីស្ដេចចូលទៅព្រៃតាំងពីព្រលឹមរកបេះផ្លែឈើ បេះបានពេញកញ្ជើ ហើយ ទើបគិតថា អញនឹងត្រឡប់ទៅបណ្ណសាលាវិញ ក៏ចូលទៅឈប់ក្រោម

ដើមជ្រៃ ដើម្បីសំរាកកាយ ។ ខណៈនោះមានយក្ស ១ ឈ្មោះពលាហកៈ អាស្រ័យនៅនឹងដើមជ្រៃនោះ យក្សក៏ស្ទុះចូលទៅចាប់ព្រះហស្ថព្រះនាងជាប់ ព្រះនាងទតព្រះនេត្រទៅឃើញរូបយក្សនោះ ក៏ភ័យស្លុតរន្ធត់ខ្លាចសេចក្ដីស្លាប់ ពន់ប្រមាណទើបទ្រង់ព្រះពិលាបសោយសោកបោកខ្លួនទឹកអាល័យដល់ព្រះ-ពោធិសត្វ។ ពេលនោះព្រះពោធិសត្វចាំមើលផ្លូវព្រះមាតាយូរពេក ព្រះអាទិត្យជិតអស្តង្គតទៅហើយ ក៏គិតថាព្រះមាតាប្រាកដជាមានហេតុអ្វីមួយបៀតបៀនពុំខាន លុះគិតដូច្នេះហើយ ក៏ក្រោកដើរទៅក្នុងព្រៃ ស្រែកហៅរកព្រះមាតា១ បានឮសម្លេងព្រះពោធិសត្វទើបស្រែកប្រាប់ថាម្នាលកូនសំឡាញ់ម្ដាយ១ នៅក្នុងទីនេះ ព្រះពោធិសត្វក៏ស្ទុះចូលទៅ ឃើញមាតាអង្គុយជិតយក្សដូច្នោះក៏មានព្រះទ័យសោមនស្សត្រេកអរ ហាក់ដូចបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃស្អែក ។ ព្រះពោធិសត្វចូលទៅជិតហើយនិយាយថា បពិត្រមហាយក្ស សូមអញ្ជើញទំពារស៊ីនូវខ្ញុំចុះសូមលោកប្រោសប្រណីលែងព្រះមាតាឆាប់១ យក្សឆ្លើយថា នៃមហាបុរសបើយ៉ាងហ្នឹងមែន ចូរអ្នកពុះទ្រូងយកសាច់បេះដូងមកឱ្យយើងស៊ីឥឡូវនេះ ។ ព្រះពោធិសត្វឮដូច្នោះទើបគិតថាអញបានកាំបិតពីណាអេះក៏សំឡឹងមើលទៅអាកាសទឹកប្ញូងសួងថា:

**គតញ្ញុតាយ តេជេន ពុទ្ធោ ហោមិ អនាគតេ**

**ឯតេន សច្ចវជ្ជេន សត្ថំ បតតុ មេ មុខេ**

ខ្ញុំសូមឱ្យបានជាព្រះពុទ្ធ ១ ព្រះអង្គក្នុងកាលអនាគត ដោយតេជានុភាពនៃកតញ្ញូកតវេទិតាធម៌របស់ខ្ញុំនេះ សូមឱ្យកាំបិតធ្លាក់ចុះមកក្នុងទីចំពោះមុខ

ខ្ញុំកុំខានដោយពាក្យសច្ចៈនេះ ។

កាំបិតដ៏មុតក៏ធ្លាក់ចុះពីអាកាសមក មួយរំពេចទើបព្រះពោធិសត្វនិយាយបញ្ជាក់ដល់យក្សទៀតថា ចូរអ្នកឱ្យជីវិតរបស់ខ្ញុំដល់មាតាខ្ញុំកុំខាន ។ គ្រានោះព្រះមាតា អង្វរឃាត់ព្រះពោធិសត្វកុំឱ្យធ្វើដូច្នោះ ព្រះពោធិសត្វក៏ដំកល់ពាក្យព្រះមាតាទុកលើត្បូង ហើយចាប់កាំបិតពុះទ្រូងរបស់ព្រះអង្គទាញបេះដូងចេញមកទើបអធិដ្ឋានថា:

**កតញ្ញុតាយ តេជេន ពុទ្ធោ ហោមិ អនាគតេ**

**ហទយំ ខាទតុ យក្ខំ មា មេ យក្ខ ន ជីវតុ**

ខ្ញុំសូមឱ្យបានត្រាស់ជាព្រះពុទ្ធ១ព្រះអង្គក្នុងអនាគត ដោយអំណាចកតញ្ញូកតវេទិតាធម៌របស់ខ្ញុំនេះ បពិត្រយក្សអ្នកអញ្ជើញពិសាទូវបេះដូងខ្ញុំចុះ សូមជីវិតរបស់ខ្ញុំកុំអាលរលត់ឡើយ ។

ឯយក្សក៏ទទួលសាច់បេះដូងនោះទៅបរិភោគអស់ឥតមានសល់ឡើយ ហើយនាំព្រះមាតារបស់ពោធិសត្វមកប្រគល់ឱ្យព្រះពោធិសត្វវិញ ។ ព្រះពោធិ-សត្វបានជួបនឹងមាតាហើយក៏នាំទៅអង្គុយក្រោមដើមឈើមួយ ទើបថ្វាយបង្គំទូលព្រះមាតាថា ចាប់តាំងពីថ្ងៃដែលខ្ញុំមកជ្រកនៅក្នុងផ្ទៃរហូតមកដល់ថ្ងៃនេះ សេចក្ដីភ្លាំងភ្លាត់របស់ខ្ញុំដោយកាយវាចាចិត្តឯណា សូមព្រះមាតាមេត្តាអភ័យទោសនោះដល់ខ្ញុំ លុះពោលចប់ហើយក៏រលត់ស្មារតីក្នុងពេលនោះទៅ ។

គ្រានោះពិភពនៃសក្កទេវរាជ ក៏ក្ដៅក្រហាយដោយអំណាច កតញ្ញូ-កតវេទិតាធម៌របស់ព្រះពោធិសត្វ ។ ព្រះឥន្ទទ្រង់ជ្រាបហេតុដូច្នោះហើយ ទើប

ហោះចុះមកឋិតលើអាកាសត្រង់ទីដែលពលាហកយក្សនៅ ក៏ត្រាស់សួរយក្សថា នែ! ពលាហកៈ!! ហេតុអ្វីឯងធ្វើកម្មលាមកយ៉ាងនេះ នែ យក្ស! បើមហាបុរស នេះមិនបានរស់ឡើងក្នុងកាលឥឡូវនេះទេ អញនឹងទម្លាយក្បាលឯងដោយ វជិរាវុធនេះមិនខាន ។ យក្សឮដូច្នោះហើយភ័យខ្លាំងណាស់ ទើបស្ទុះទៅទទួល យកព្រះពោធិសត្វពីដៃព្រះមាតាហើយលាបស្រឡាបដោយឱសថទិព្វវិសេស ១ រំពេចព្រះពោធិសត្វក៏មានស្មារតីឡើង ទើបព្រះមាតាអធិដ្ឋានថា:

**កតញ្ញុតាយ យុត្តោសោ ពុទ្ធោ ហោមិ អនាគតេ**
**មម សច្ចានុភាវេន ជិវិតុ ជីវតុ ឱរសោ**

សេចក្តីថា: ព្រះឱរសរបស់ខ្ញុំនោះជាអ្នកតាំងមាំក្នុង កតញ្ញូកតវេទិតា ធម៌ប្រាកដជាបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតពុំខាន សូមឱ្យឱរសរបស់ខ្ញុំរស់ ឡើងក្នុងកាលឥឡូវនេះ ដោយអានុភាពនៃសច្ចវាចារបស់ខ្ញុំកុំខានឡើយ ។

កាលបើព្រះនាងអធិដ្ឋានចប់ហើយ មហាបុរសក៏មានសម្បុរផូរផង់ ដូចជាសម្បុរទិព្វ ទើបក្រោកឡើងថ្វាយបង្គំព្រះមាតាក្នុងមួយរំពេចនោះ ។

ដែលទាញនិទានជាតកមកនេះ ដើម្បីជាភ័ស្តុតាងឱ្យឃើញច្បាស់នូវ អានុភាពកតញ្ញូកតវេទិតាធម៌ ដែលបុគ្គលបានចំរើនឱ្យពេញលេញដល់កិរិតធម៌ សូម្បីស្លាប់ហើយក៏អាចមានជីវិតរស់ឡើងវិញបាន ។

ព្រោះហេតុនោះបានជា ព្រះមានព្រះភាគទ្រង់សំដែងមាននៅក្នុងគម្ពីរ មហាបដ្ឋានថា:

**កតញ្ញុតា លោកេ ធម្មមូលា កតញ្ញុតា** (១)

**លោកេ បធានតា កតញ្ញុតាយ សន្តិយា សព្វបុញ្ញតា ទិដ្ឋិ ២**

សេចក្តីថាៈ កតញ្ញូតាធមិជាឫសគល់នៃធមិក្នុងលោក កតញ្ញូតាធមិជាប្រធានក្នុងលោក ក៏បុណ្យទាំងអស់រមែងមានក្នុងកតញ្ញូតាធមិ ។

បើបុគ្គលណាមិនមានកតញ្ញូកតវេទិតាធមិទេ បុគ្គលនោះតែងជួបប្រទះតែនឹងសេចក្តីទុក្ខលំបាកក្រីក្រថោកទាបអាប់សិរីសួស្តីជានិច្ច ដូចមានរឿងមួយក្នុងគម្ពីរសំស្ក្រឹតថាៈ

កាលកន្លងទៅហើយមានមហាឫសីមួយរូបឈ្មោះ បរហំសៈ នៅក្នុងព្រៃស្ងាត់ បានឃើញកណ្តុរមួយដែលក្អែកកំពុងពាំ ។ មហាឫសីនោះបានឃើញហើយមានសេចក្តីករុណាទើបជួយសត្វកណ្តុរនោះឱ្យរួចពីមាត់ក្អែក ហើយយកមកចិញ្ចឹមដោយគ្រាប់ស្រងែ ។ កាលជាខាងក្រោយមកមានឆ្មាមួយឈ្មោះលម្ពលណៈ ស្ទុះចេញចាប់កណ្តុរនោះ កណ្តុរភិតភ័យខ្លាំងក៏រត់ចូលទៅសសុលត្រង់ទ្រូងមហាឫសី។ ដឹងថាកណ្តុរខ្លាចឆ្មាដូច្នោះ ទើបជប់កណ្តុរនោះឱ្យកើតជាឆ្មា ។ កាលជាខាងក្រោយមកឆ្មានោះខ្លាចឆ្កែទៀត មហាឫសីក៏ជប់ឆ្មានោះឱ្យកើតជាឆ្កែ ។ កាលជាខាងក្រោយនោះមកទៀត ឆ្កែបានឃើញខ្លាក៏ភ័យញាប់ញ័រទើបរត់ចូលទៅជិតមហាឫសី។ ឃើញដូច្នោះក៏ជប់ឆ្កែនោះឱ្យកើតជាខ្លា ។ កណ្តុរកាលបើមហាឫសីបានជប់បន្ត។រហូតដល់បានកើតជាខ្លាដូច្នោះ ហើយក៏ឥតមានភ័យអ្វីទៀតឡើយ តែងនៅអាស្រ័យក្បែរអាស្រមមហាឫសីនោះ ។ ជនទាំងឡាយបានឃើញខ្លានោះហើយក៏នាំគ្នានិយាយថា "ខ្លានេះកាលមុនជា

កណ្តុរ ឥឡូវមហាឫសីបានជប់ឱ្យកើតជាខ្លា ។ ឯខ្លានោះជាសត្វអកតញ្ញូបានឮពាក្យដែលជននិយាយដូច្នោះហើយក៏គិតថា "អញបើមហាឫសីនេះរស់នៅដរាបណា កិត្តិសព្ទល្អរបស់អញគ្មានឡើយ បើដូច្នោះអញត្រូវសម្លាប់មហាឫសីនេះចេញ ។ មហាឫសីលោកមានអាត្ម័នដ៏ប្រសើរ កាលបើដឹងថាខ្លាគិតដូច្នោះហើយក៏និយាយចំពោះខ្លានោះថា ឯងចូរទៅជាកណ្តុរវិញចុះ ខ្លាក្លាយទៅជាកណ្តុរដូចដើមវិញក្នុងមួយរំពេចនោះ ក៏ដល់នូវសេចក្តីសាបសូន្យចាកសេចក្តីសុខដរាបដល់អស់ជីវិតមហាឫសីលោកឈប់ត្រូវការតាំងពីពេលនោះហោង ។

នេះជាទោសស្តួចស្តើងព្រោះគ្រាន់តែគិតក្នុងចិត្តពុំទាន់បានសម្លាប់ ហេតុដូច្នេះគួរតែកំចាត់បង់អកតញ្ញូតាធម៌ កុំគប្បីឱ្យកើតមានឡើយ ។

អធិប្បាយមកអំពីធម៌ជាប្រធានក្នុងលោកបីយ៉ាងគឺ **សច្ចំ ខន្តិ កតញ្ញុតា** សង្ខេបតែប៉ុណ្ណេះ ។ ធម៌បីនេះបើបានចំរើនឱ្យកើតឡើងក្នុងវេលាជាមួយគ្នាអាចឱ្យផលជាក់ស្តែងក្នុងបច្ចុប្បន្ន ដោយពិតប្រាកដដូចមាននិទានមួយក្នុងគម្ពីរមហាបដ្ឋានថាៈ

ក្នុងកាលកន្លងទៅហើយមានសេដ្ឋីម្នាក់ស្នាក់នៅក្នុងដែនកោសល សេដ្ឋីនោះមានគោមេមួយឈ្មោះ ពហុលា មានកូនខ្ចី ។

ថ្ងៃមួយគោមេនោះនាំកូនចូលទៅស៊ីស្មៅក្នុងដងព្រៃ លុះចូលជ្រៅបន្តិចទៅបានលាក់កូនទុកក្នុងទីមួយក៏ចូលទៅក្នុងព្រៃធំ ដើម្បីស៊ីស្មៅខ្ចីដែលទើបតែនឹងលាស់ក្នុងវស្សន្តរដូវ ។ គោមេនោះកំពុងតែស៊ីស្មៅស្រាប់តែប្រទះនឹងខ្លាធំមួយ ក៏ភិតភ័យញ័រចំប្រប់ ខ្លាបំរុងស្ទុះទៅចាប់ស៊ី គោមេនោះអង្វរថា

សូមលោកមេត្តា បើកឱកាសឱ្យខ្ញុំបន្តិច ព្រោះខ្ញុំមានកូនខ្ចីលាក់នៅទីនុ៎ះ ខ្ញុំនឹងទៅឱ្យកូនបៅសិន កាលបើបៅហើយខ្ញុំត្រឡប់មកឱ្យលោកស៊ីនៅទីនេះវិញ នេះជាពាក្យសច្ចៈរបស់ខ្ញុំ ខ្លាក៏ព្រមឱ្យទៅ ។ គោមេនោះកាលបើខ្លាបើកឱកាសឱ្យដូច្នោះហើយខំម្នីម្នាស្ទុះទៅរកកូនឱ្យបៅឆ្អែតទើបប្រាប់ថា ម្នាលកូនអ្នកនៅរកស៊ីស្មៅខ្ចីក្បែរព្រៃនេះចុះម្ដាយត្រូវជាចំណីខ្លាហើយ ប្រាប់កូនតែប៉ុណ្ណេះក៏ដើរទៅឱ្យខ្លាស៊ី ដើម្បីកុំឱ្យដាច់ពាក្យសច្ចៈ កូនគោខំស្ទុះតាមទៅៗ ឈរជិតមាត់ខ្លាទើបនិយាយថា: លោកស៊ីខ្ញុំចុះ ទុកម្ដាយខ្ញុំឱ្យគាត់រស់នៅព្រោះគាត់មានគុណលើរូបខ្ញុំធ្ងន់ណាស់ ។ ខ្លាឮដូច្នោះក៏នឹកស្ងើចក្នុងចិត្តថា អើហ្ន ! កូនគោនេះមិនខ្លាចស្លាប់សោះមេវាក៏មិនខ្លាចស្លាប់ដែរ បើដូច្នេះមុខតែវាមានទីពឹងអ្វីមួយមិនខានទើបសួរទៅមេគោថា នាងបានអ្វីជាទីពឹង ? មេគោប្រាប់ថាគ្មានអ្វីទេ បានជាខ្ញុំមកឱ្យអ្នកស៊ីវិញ ព្រោះខ្ញុំរក្សាសច្ចៈធម៌ ទើបសួរទៅកូនគោទៀត កូនគោប្រាប់ថាខ្ញុំរក្សាកតញ្ញូតាធម៌ ខ្លាក៏សួរអំពីប្រយោជន៍របស់ធម៌ទាំងពីរមេគោនិយាយប្រាប់សព្វគ្រប់ទើបខ្លាខំអត់ទ្រាំមិនស៊ីគោទាំងពីរ ហើយរាប់អានគ្នាជាមិត្រយ៉ាងស្និទ្ធស្នាល ។ កាលបើសត្វទាំងបីគឺ មេគោរក្សាសច្ចៈធម៌.កូនគោរក្សាកតញ្ញូតាធម៌. ខ្លារក្សាខន្តិធម៌ដូច្នេះហើយក៏ក្ដៅក្រហាយដល់អាសនៈរបស់សក្កទេវរាជ ដោយអំណាចធម៌ទាំងបីនេះព្រះឥន្ទ្រទ្រាំមិនបានទើបហោះចុះមកពោលសរសើរថា:

**នត្ថិ សច្ចសមំ បុញ្ញំ នត្ថិ ខន្តិសមំ សច្ចំ**
**កតញ្ញូតាសមំ ខន្តិ នត្ថិ តិវិធំ ឧត្តមំចរំ**

សេចក្តីថា បុណ្យមិនស្មើនឹងសច្ចៈធម៌ មិនស្មើនឹងខន្តិធម៌ មិនស្មើនឹង កតញ្ញុតាធម៌. ធម៌ទាំងបីនេះជាធម៌ប្រសើរវិសេសផុតក្នុងលោក ។

ក្នុងពេលនោះសក្កទេវរាជបាននាំសត្វទៅកាន់តាវតឹង្សទេវលោក ទៅដល់ពេលណាវិមានប្រាសាទភ្លេងតូរ្យតន្ត្រីនឹងកោដិនៃស្រីអប្សរទាំងឡាយ ក៏ផុះឡើងទទួលដោយអំណាចនៃធម៌ទាំងបី. មេគោ កូនគោ ខ្លាធំ ក៏ក្លាយភេទជាទេវបុត្រទេវធិតាហើយសោយទិព្វសម្បត្តិក្នុងទេវលោកនោះហោង ។

ក៏ធម៌ទាំងបីគឺ **សច្ចំ ខន្តិ កតញ្ញុតា** នេះ បើមាននៅភូមិ ស្រុក ខែត្រ ប្រទេសណាហើយ ភូមិ ស្រុក ខែត្រ ប្រទេសនោះនឹងសម្បូណ៌ដោយវឌ្ឍនភាពធាត់ធំលូតលាស់ឡើង មានឫទ្ធិរុទ្រ ដោយមហុត្តកាលមិនអាចប្រែក្លាយទៅជាប្រទេសទាបទាសស្ទុត្រទ្រុឌឡើយ ដូចភ្នំសិណេរុស្តែដែលមានកំពស់ ៨ ហ្មឺន ៤ ពាន់យោជន៍ ខ្ពស់ស្កឹមស្កៃលូតលេចទៅក្នុងនភាល័យ ទោះបីមានខ្យល់ព្យុះព្យោមាបក់បោកមកអំពីទិសទាំង ៨ ក៏មិនអាចញាំញីធ្វើភ្នំនោះឱ្យញាប់ញ័របានឡើយ ដោយមានឫសបីទល់ទ្រទប់ពីក្រោមយ៉ាងណាមិញ ត្រៃកូដធម៌ទាំងបីទុកដូចជាទ្នល់ទល់ទ្រពិភពលោក មិនឱ្យអនុវត្តទៅរកហីនភាព ក៏ដូច្នោះដែរ ។ ធម៌ទាំងបីនេះ បើសំដែងដោយឧក្រិដ្ឋឃើញថាមានអត្ថដ៏ជ្រាលជ្រៅពន់ពេកន័យខ្លះព្រះសម្ពុទ្ធទ្រង់សំដែងថា សច្ចៈ រម្ងាប់ **លោភៈ** ខន្តិរម្ងាប់ **ទោសៈ** កតញ្ញុតារម្ងាប់ **មោហៈ** ។

សំដែងមកក្នុងធម៌ទាំងបីគឺ សច្ចំ ខន្តិ កតញ្ញុតា ដែលហៅថាត្រៃកូដធម៌ ឧត្តមវរធម៌ ឬបធានធម៌ ក៏សន្និដ្ឋានថាចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

អធិដ្ឋានគាថា

**សព្វេ សត្តា អវេរា ច អព្យាបជ្ឈា ច និទ្ទុក្ខា**

**ចរិយា សុខិតា សព្វេ និព្វាយន្តិ ច សព្វទា ។**

សត្វទាំងឡាយទាំងពួង កុំឱ្យមានពៀរវេរានឹងគ្នា កុំឱ្យមានទុក្ខ កុំឱ្យមានភ័យ សូមឱ្យពួកសត្វនិករទាំងអស់បានប្រកបដោយសុខភាពដ៏ប្រសើរ ឱ្យបានរំលត់ទុក្ខសព្វៗ កាល ! ។

**ចប់ត្រៃភូជធម៌**

១-ចម្លងតាមច្បាប់ដើមមិនហ៊ានកែ

មានលក់ដុំនិងរាយនូវសៀវភៅគ្រប់
ប្រភេទ ជាពិសេស សៀវភៅធម៌
តូបលេខ ៥ & ៦៥
ផ្សារអូឫស្សី ក្រុងភ្នំពេញ